# **ធម្មៈ ជាមួយនឹងការខ្លាចកូវីដ១៩**

ឌីជេ បញ្ញូន វិឆៀនស្រី អ្នករៀបចំកម្មវិធី "ភ្លក់កាហ្វេនៅឯសភា »

ស្ថានីយវិទ្យុមហាវិទ្យាល័យ សុងខ្លានគរិន្ទ្រ

សាខាហាតយ៉ៃ

ប្រទេសថៃ

សន្ទនាជាមួយអាចារ្យ **សុចិន្ត បរិហារវនខេត្ត**

ថ្ងៃសៅរ៍ ទី២១ ខែមីនា ព.ស២៥៦៣


លោកអាចារ្យ **សុចិន្ត បរិហានវនខេត្ត**

ប្រសូត នៅថ្ងៃ ១៣ ខែមករា គ.ស១៩២៧ នៅខេត្តឧប៊ុនរាជធានី ប្រទេសថៃ

ជាគ្រូបង្រៀនព្រះធម៌ តាំងពីគ.ស១៩៥៦ មក

https://www.dhammahome.com/



បកប្រែដោយ សមាជិក**មូលនិធិសិក្សានិងផ្សព្វផ្សាយព្រះពុទ្ធសាសនា** ២រូប

**ខែ កក្កដា គ.ស២០២០**

**ឌីជេ បញ្ញូន វិឆៀនស្រី** ៖ អាចារ្យសុចិន្ត នៅក្នុងសង្គមយើងរាល់ថ្ងៃនេះ មិនថាសង្គមពិភពលោក ឬសង្គមថៃក៏ដោយ យើងមានអារម្មណ៍ថាខ្វាយខ្វល់ ភ័យខ្លាចជាមួយនឹងអ្វីៗទាំងឡាយដែលកើតឡើងនៅជុំវិញខ្លួន ហើយយើងមិនដឹងថា វាជាអ្វីឱ្យពិតប្រាកដ ហើយវានឹងមានទីបញ្ចប់ត្រឹមណា។ អាចជាការឈឺចុកចាប់ ការស្លាប់ ជាពិសេសនៅអំឡុងពេលនេះយើងបានឮពីកូវី-ដ១៩ ក៏ជាព័ត៌មានដែលល្បីពាសពេញពិភពលោក ទាំងភូមិភាគខាងត្បូង ក៏មានហេតុការណ៍ដែលទាក់ទងនឹងភាពអសន្តិសុខក្នុងទឹកដី៣ខេត្ត ហើយជនជាតិថៃក៏ខ្វល់ខ្វាយ។ អ្នកមកពីកន្លែងផ្សេងគ្នា ពេលដែលមកដល់ទឹកដីភាគខាងត្បូង ឬមកហាតយ៉ៃ ក៏ខ្វល់ខ្វាយថានឹងមកជួបជាមួយនឹងរឿងបែបនេះឬទេ? តែយកតាមការយល់ពិតៗហើយនោះ សូម្បីតែជីវិតប្រចាំថ្ងៃ ក្តីក្តាំ អាជ្ញាកម្ម ឧបទ្ទវហេតុទាំងឡាយ ក៏ជាភ័យដែលនៅជុំវិញខ្លួនយើងគ្រប់ពេលវេលា។ ដូចនេះកណ្តាលភាពភ័យខ្លាចផ្សេងៗទាំងនេះ យើងគួរពិចារណា រឿងដែលកើតឡើងជុំវិញខ្លួនរបស់យើង យ៉ាងដូចម្តេចបាន នៅក្នុងផ្លូវរបស់ព្រះពុទ្ធសាសនាបាទ?

**លោកអាចារ្យ សុចិន្ត បរិហានវនខេត្ត** ៖ ចាស សេចក្តីពិតបំផុតក៏គឺថា តើមាននរណាបង្ការបញ្ហាមិនឱ្យកើតបានទេ? នៅពេលដែលកើតឡើងហើយ ឃើញទេ ចាស យើងត្រូវតែពិចារណាឱ្យបានដល់ដើមហេតុ ពិតៗថា យើងមិនបានយល់ហើយថា រាល់រឿងរ៉ាវគ្រប់យ៉ាង មិនមាននរណាអាចនឹងធ្វើអ្វីបានឡើយ ក្រៅតែពីមានហេតុបច្ច័យនឹងឱ្យរឿងនោះកើតឡើង រឿងនោះទើបនឹងអាចកើតឡើងបាន។ មើលទៅដូចរឿងធម្មតា តែថាសេចក្តីពិតនោះ គឺជ្រាលជ្រៅ គឺថាទោះមានភ័យ ឬមិនមានភ័យយ៉ាងណា ក៏ត្រូវតែ មានការឃើញ មានការឮ មានការនឹកគិត ហាមមិនបានឡើយ។ ប៉ុណ្ណេះនៅហាមមិនបានផង ហើយនឹងទៅហាមភ័យអ្វីបាន ចាស? នៅពេលដែលមានបច្ច័យដែលនឹងកើតឡើងក៏កើត កើតឡើងឱ្យឃើញផងថា នរណាក៏ធ្វើអ្វីមិនបានឡើយ បង្ការបញ្ហាមិនបាន បានត្រឹមតែថា ប្រសិនបើយល់ការពិតថា គ្រប់យ៉ាងមិនបានទៅតាមអ្វីដែលយើងគិត ឬយើងត្រូវការ[ឡើយ] តែគ្រប់យ៉ាង មានហេតុដែលនឹងឱ្យកើតឡើងជាយ៉ាងណា ក៏ត្រូវតែជាយ៉ាងនោះ។ ហើយឧទាហរណ៍ក៏ច្បាស់លាស់គ្រប់សម័យ ប្រសិនបើមិនមានកូវីដ យើងក៏គិតរឿងដទៃ ហើយក៏ភ្លេចរឿងនេះ តែមិនថាអ្វីក៏ដោយដែលនឹងកើតឡើង តើនរណាធ្វើឱ្យកើតបាន? មិនមាននរណាម្នាក់ សូម្បីតែម្នាក់ឡើយ ប៉ុន្តែកើតឡើងផ្សេងវិញ ហើយយើងក៏នឹងដឹងតាមពិតៗថា នរណានឹងដឹងដល់ហេតុ ដែលនរណាក៏បង្ការបញ្ហាមិនបាន ព្រោះត្រូវតែយ៉ាងនេះ ចាស។

**ឌីជេ** ៖ ការដែលយើងខ្លាចភយន្តរាយដែលកើតឡើងជុំវិញខ្លួនយើង ហើយយើងគេចវេសនឹងប្រឈមមុខ ចាត់ថាជាវិធីដែលត្រឹមត្រូវទេ បាទ?

**សុចិន្ត** ៖ គ្មានផ្លូវធ្វើអ្វីបានទេ ចាស។ នឹងគេចវេសយ៉ាងម៉េច ចាស? ប្រសិនបើប្រើវិធីការពារ គេក៏ការពារ តែទោះជាយ៉ាងណា ដល់ពេលដែលនឹងកើត ក៏កើតបាន មែនទេ ចាស? ត្រឹមតែយើងមិនប្រមាទ ព្រោះយើងស្គាល់ហេតុដែលពិតប្រាកដ ថាគ្រប់យ៉ាងកើតឡើងមកបានយ៉ាងណា តាមពាក្យដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្តែងយ៉ាងល្អិតល្អន់យ៉ាងក្រៃលែងថា គ្រប់យ៉ាងដែលយើងមិនដឹងថាកើតឡើងបានយ៉ាងដូចម្តេច ព្រះអង្គទ្រង់សម្តែងហេតុ ទាំងហេតុជិត ទាំងហេតុឆ្ងាយ យ៉ាងល្អិតល្អន់។ ព្រោះដូច្នោះ ប្រសិនបើមិនមានការចេះដឹង យើងក៏នឹងខ្លាចតែទាំងអស់ ដូចថ្ងៃនេះយើងខ្លាចជំងឺនេះ និងតទៅខាងមុខមានជំងឺផ្សេង យើងក៏ខ្លាចទៀត មែនទេចាស? ខ្លាចទាំងអស់ ព្រោះមិនដឹងការពិតថា ហេតុដែលនឹងឱ្យកើតរឿងល្អក៏មាន ហេតុដែលនឹងឱ្យកើតរឿងដែលមិនល្អក៏មាន។ ហេតុអ្វីកើតឡើងជាមួយអ្នកនេះល្អ កើតឡើងជាមួយអ្នកដទៃទៀតមិនល្អ? ហេតុអ្វីមនុស្សទូទាំងពិភពលោកមិនកើត តែហេតុអ្វីអ្នកខ្លះកើត ដូចជាជំងឺនេះមិនកើតគ្រប់គ្នា មែនទេចាស? ហើយភាពភ័យខ្លាច ត្រូវតែមានពិតប្រាកដ ដរាបណាមានការស្រឡាញ់ខ្លួនមែនទេចាស? កើតមកនេះក៏ខ្លាចតែទាំងអស់ នឹងខ្លាចតិចខ្លាចច្រើនក៏តាមហ្នឹង។

**ឌីជេ** ៖ ពេលដែលនិយាយរឿងមិនប្រមាទ សម្រាប់ខ្ញុំ សម្រាប់មនុស្សទូទៅ ខ្ញុំក៏សង្កេតឃើញថា មិនប្រមាទគឺថា យើងដឹងថា យើងឃើញអ្នកភ័យ ដូចដែលយើងខ្លាចៗនេះឯងខ្លាចឧបទ្ទវហេតុ ខ្លាចអាជ្ញាកម្ម ខ្លាចជំងឺឈឺដង្កាត់ ខ្លាចភ័យវិបត្តិផ្លូវធម្មជាតិ ហើយខ្ញុំក៏នឹងគេចវេសនឹងជួបវា ខ្ញុំកាន់យកថា វាជាសេចក្តីមិនប្រមាទ។

**សុចិន្ត** ៖ អ្នកដែលកើតកូវីដ គេគេចវេសឬទេ? តែគេក៏កើតមែនទេ? ឬគេមិនអាចគេចវេសគេក៏ត្រូវតែកើតមែនទេ? ព្រោះដូច្នេះ តាមពិតទៅក៏មានហេតុដែលអាចឱ្យឃើញជិតៗថា បើបណ្តោយខ្លួន មិនប្រយ័ត្នខ្លួន ក៏មានផ្លូវដែលនឹងអាចកើតឡើងបាន តែហេតុដែលឆ្ងាយជាងនោះទៅទៀតនោះគឺថា អ្នកដែលប្រយ័ត្នហើយនៅតែកើតបាន ព្រោះអ្វី? និងអ្នកដែលមិនប្រយ័ត្នខ្លួនយ៉ាងនោះ តែដល់ពេលមិនកើតក៏មិនកើត ឬកើតគ្រប់គ្នា ឬអ្នកដែលខ្លាចអ្នកដែលប្រយ័ត្នប៉ុណ្ណោះដែលមិនកើត និងអ្នកដែលកើតនោះ មិនប្រយ័ត្នប៉ុណ្ណោះឬយ៉ាងណាចាស?

**ឌីជេ** ៖ អ្នកដែលប្រយ័ត្នក៏កើត តាមដែលខ្ញុំបានឮព័ត៌មានមក។

**សុចិន្ត** ៖ ព្រោះដូច្នេះ ប្រយ័ត្នយ៉ាងណាក៏កើតបាន ប្រសិនបើដល់ពេលដែលនឹងកើត។ តែថា ប្រសិនបើមិនទាន់ដល់ពេលដែលកើត យ៉ាងណាក៏មិនកើត តែមិនកើតសោះនោះ មិនអាចទៅរួចទេ ព្រោះថាដែលកើតមកនេះ គឺកើតហើយ នឹងកើតទៅរឿយៗគ្រប់ខណៈ មែនទេចាស? មិនថាអ្វីនឹងកើតឡើង កើតល្អ កើតអាក្រក់ ជាទុក្ខ ជាសុខ ផ្សេងៗទាំងនេះ ក៏ជាយ៉ាងនេះប្រាកដណាស់ មិនមែនកើតបានល្អទៅរហូតទេ ឬការកើតទុក្ខវិញ អ្នកខ្លះក៏ទុក្ខកាយ តែចិត្តមិនកើតទុក្ខឡើយ អ្នកខ្លះក៏លំបាកចិត្តណាស់ តែកាយមិនកើតទុក្ខឡើយ។ ទាំងអស់នេះគឺមិនស្គាល់ហេតុថា របស់គ្រប់យ៉ាងនេះកើតឡើងយ៉ាងដូចម្តេច។ ដូច្នេះ នៅពេលដែលមិនដឹងហេតុ ក៏មិនដឹងថា « ហេតុ » អ្វីដែលនឹងឱ្យផលដែលល្អកើតឡើងបាន « ហេតុ »អ្វីដែលនឹងឱ្យផលមិនល្អកើតឡើងបាន។

**ឌីជេ** ៖ ប្រសិនបើស្តាប់តាម[ដែល]អាចារ្យមានប្រសាសន៍ ហើយនឹកទៅទូទៅៗ ខ្ញុំក៏ដូចដឹងថា បើអញ្ចឹងយើងក៏មិនចាំបាច់ធ្វើអ្វីឡើយ ព្រោះថា ហេតុ វាត្រូវកើត វាក៏ត្រូវកើតខ្លួនវាស្រាប់ហើយ មិនឃើញត្រូវចាំបាច់ត្រូវទៅគេចវេស ឬប្រយ័ត្នប្រយែងអ្វីឡើយ វាដូចជាការប្រមាទដែរទេអញ្ចឹង?

**សុចិន្ត** ៖ ឃើញអត់ចាស ចាប់ផ្តើមគិតខុសហើយចាស តាមការដែលមិនចេះដឹង ក៏គឺគិតថា ប្រសិនបើយ៉ាងនោះក៏មិនចាំបាច់ធ្វើអ្វី ប៉ុន្តែគិតអត់ទេថា ត្រូវធ្វើអំពើល្អ ត្រូវតែជាមនុស្សល្អ ព្រោះជាហេតុដែលនាំឱ្យរឿងដែលល្អ ត្រឹមត្រូវទេចាស?

**ឌីជេ** ៖ បាទ

**សុចិន្ត** ៖ ព្រោះដូច្នេះ យើងរំលងចាស យើងទៅសម្លឹងមើលហេតុជាទូទៅៗ ការពាររោគ ឬអ្វី តើហេតុដែលធំជាងនោះក៏គឺថា រឿងដែលជាហេតុដែលល្អយ៉ាងណាៗ ផលក៏ត្រូវតែល្អជាប្រាកដ និងចំណែកផលដែលមិនល្អ ទោះនឹងធ្វើយ៉ាងណា ក៏ត្រូវតែមិនល្អចាស។ ហេតុអ្វីមនុស្សយើងកើតមក មិនទាន់មានរោគកូវីដឡើយ ឬរោគអ្វីទាំងអស់ ប៉ុន្តែពិការក៏បាន អ្វីដទៃក៏បានគ្រប់យ៉ាង គិតថានឹងស្លាប់ដោយរោគនេះ ក៏មិនមែន ស្លាប់ដោយរោគផ្សេងក៏បាន ឬមិនមានរោគអ្វីក៏ស្លាប់បើបាន ព្រោះហេតុដូច្នោះ គ្រប់គ្នាប្រាថ្នាតែរឿងដែលល្អ តែមិនដឹងថា ហេតុដែលនឹងឱ្យកើតរឿងល្អនោះគឺអ្វី។ ព្រោះដូច្នេះ ហេតុដែលមានមកតាំងពីយូរ

យាណាស់មកហើយ គឺហេតុដែលល្អនឹងត្រូវឱ្យផលដែលល្អ ស្មើរហូតទៅ ហេតុដែលមិនល្អក៏ត្រូវឱ្យផលមិនល្អ ស្មើរហូតទៅ យ៉ាងនេះមិនខុសទេ មែនទេចាស?

**ឌីជេ** ៖ មិនខុសទេបាទ

**សុចិន្ត** ៖ តែយើងភ្លេច។ យើងគិតថា ប្រសិនបើយ៉ាងនោះក៏មិនចាំបាច់ធ្វើអ្វី ខណៈដែលមិនចង់ធ្វើអ្វីក៏គឺថាមិនល្អដោយពិត ព្រោះហេតុថា មិនដឹងថាគួរធ្វើអំពើល្អ។

**ឌីជេ** ៖ មានន័យថា បើគិតថាមិនចាំបាច់ធ្វើអ្វី បណ្ដោយទៅ មានន័យថា សូម្បីតែធ្វើល្អ ក៏មិនបានធ្វើ?

**សុចិន្ត** ៖ ចាស គិតខុសចាស បណ្ដោយទៅ ឃើញទេចាស បណ្ដោយទៅ ក៏ត្រូវមិនល្អទៅរឿយៗ ព្រោះយើងមិនមានការយល់ដែលត្រឹមត្រូវ។ ខណៈដែលបណ្ដោយទៅនោះ ធ្វើល្អឬអត់? ឃើញទេចាស? តែបើធ្វើល្អ ក៏មិនមែនបណ្ដោយទៅ។ ដូចជាពេលនេះមានរោគកូវីដ នរណាៗ ក៏ជួយគ្នា មើលថែយកចិត្តទុកដាក់ដល់គ្នានឹងគ្នា មិនទុច្ចរិតជាមួយរឿងអ្វីផ្សេងៗឡើយ ទាំងនេះក៏រមែងបន្ធូរបន្ថយទៅសន្សឹមៗ តែប្រសិនបើមានរឿងដែលមិនល្អកើតឡើង ក៏កាន់តែធ្វើឱ្យស្ថានការណ៍នេះមិនល្អ។ ព្រោះដូច្នេះ ចំណុចដែលសំខាន់បំផុតដែលមនុស្សភ្លេច ក៏គឺ សេចក្ដីល្អ សេចក្ដីអាក្រក់ ដែលជាហេតុពិតប្រាកដ តែគេសម្លឹងមើលមិនឃើញ គេទៅជាគិតត្រឹមតែថា នឹងការពារខ្លួនប៉ុណ្ណោះ តែចិត្តការពារឬអត់ ដែលនឹងមិនធ្វើរឿងដែលមិនល្អ។

**ឌីជេ** ៖ អំពើល្អ ឬរឿងដែលល្អ យើងប្រមើលមើលបានដោយសារអ្វីខ្លះ បាទ? ខ្ញុំធ្លាប់ឃើញរឿងមួយចំនួនដែលអ្នកខ្លះថាជាសេចក្ដីល្អ ក្នុងខណៈដែលអ្នកដទៃទៀតដែលមិនយល់ស្រប លើកឡើងថាមិនមែនទេ ហើយថាសេចក្ដីល្អរបស់គេជារឿងដទៃទៀត។

**សុចិន្ត** ៖ ព្រោះដូច្នោះ សេចក្ដីល្អរបស់អ្នកដែលមិនធ្លាប់ស្ដាប់ព្រះធម៌សោះឡើយ ជាមួយនឹងសេចក្ដីល្អរបស់អ្នកដែលបានស្ដាប់ព្រះធម៌ ហើយយល់ក្នុងហេតុនិងផល ក៏ត្រូវតែផ្សេងគ្នា មែនទេ ចាស?

**ឌីជេ** ៖ បាទ

**សុចិន្ត** ៖ ព្រោះដូច្នេះ គេមិនរៀនឱ្យដឹងហេតុដែលពិតប្រាកដឡើយ សូម្បីតែខណៈនេះឯងបានឮសំឡេង បង្គាប់បញ្ជាបានអត់មិនឱ្យបានឮវិញ ។

**ឌីជេ** ៖ មិនបានទេបាទ ។

**សុចិន្ត** ៖ ចាស ព្រោះហេតុដូច្នោះ គ្រប់យ៉ាងដូចកើតឯកឯង តែសេចក្តីពិត មិនមែនឡើយ។ ព្រោះថា សំឡេងក្នុងព្រៃក៏មាន សំឡេងឆ្ងាយៗក៏មាន សំឡេងក្នុងបន្ទប់ក៏មាន ម្នាក់មួយបន្ទប់ ប៉ុន្តែសំឡេងដែលបានឮ ត្រូវតែជាសំឡេងដែលមិនមែនសំឡេងដទៃ ប៉ុន្តែជាសំឡេងដែលជាក់ស្តែង ធ្វើឱ្យបានឮសំឡេងនោះកើតឡើង នឹងជាសំឡេងល្អ ឬមិនល្អ ល្អិតល្អន់ណាស់ ចាស។ ប្រសិនបើយើងចែកពេលតែមួយខណៈ ចុះមកខ្លីៗ ជាការឃើញ ជាការឮ ជាការនឹកគិត ដែលកើតរលត់ផ្លាស់ប្តូរលឿនរហ័សណាស់ក្នុងមួយថ្ងៃៗ មិនមានអ្វីដែលនៅស្ងៀម ឬឋិតថេរឡើយ ព្រោះយើងមិនដឹងចាស ព្រោះថាជាប់គ្នាទាំងអស់រហូតដល់មើលមិនឃើញថា អ្វីកើតឡើង អ្វីរលត់ទៅ ព្រោះតគ្នាលឿនណាស់។ ព្រោះហេតុនេះអម្បាញ់មិញយើងនិយាយរឿងនេះ ហើយយើងក៏និយាយគ្នារឿងផ្សេងមួយទៀត ឃើញទេចាស? រឿងផ្សេងអស់ហើយ ព្រោះដូច្នេះរឿងកូវីដក៏ជារឿងមួយ។ ប្រសិនបើយើងដេកលក់ស៊ប់ ក៏មិនដឹង មិនឃើញអ្វី ប៉ុន្តែនៅពេលភ្ញាក់ឡើងក៏ខ្វាយខ្វល់ ដោយសេចក្តីស្រឡាញ់ខ្លួនឯង ស្រេចតែការខ្វាយខ្វល់ នោះនឹងធ្វើដើម្បីខ្លួនឯង ឬនឹងធ្វើដើម្បីអ្នកដទៃ ក៏មានច្រើនមូលហេតុ តែនាងខ្ញុំគិតថា ប្រសិនបើរាល់គ្នា មានការយល់ដឹងក្នុងសេចក្តីល្អ និងធ្វើល្អ នោះមិនខ្លាចអ្វីឡើយ។

**ឌីជេ** ៖ ប្រសិនបើដូច្នោះមានន័យថា ភ័យដែលពិតប្រាកដ ដែលយើងគួរដឹងច្បាស់ មិនមែនភ័យដែលមនុស្សទូទៅៗ កំពុងមានអារម្មណ៍ នៅពេលនេះថា ខ្លាចរឿងនោះ ដែលជាបច្ច័យខាងក្រៅយ៉ាងនេះយ៉ាងនោះ ខ្លាចការផ្លាស់ប្តូរយ៉ាងនេះយ៉ាងនោះ យ៉ាងនោះមែនឬទេបាទ?

**សុចិន្ត** ៖ ចាស ព្រោះម្នាក់ៗខ្លាចគ្នា អញ្ចឹងហើយ តែភ័យនឹងកើតជាមួយនរណាចាស ពាក្យនេះ ត្រូវសម្រាប់អ្នកដែលភ័យនោះនឹងកើតឡើងជាមួយនឹងគេមែនទេចាស? មិនយ៉ាងនោះ ពេលនេះរាល់គ្នាក៏កើតទៅទាំងអស់គ្នាបាត់ហើយ។ ព្រោះដូច្នោះ មិនថាអ្វីនឹងកើតឡើងជាមួយនរណា ក៏ត្រូវតែហេតុចំពោះតែអ្នកនោះ អ្នកនោះតែម្នាក់ៗតែប៉ុណ្ណោះ ជារឿងដែលល្អិតល្អន់ណាស់ តែទាំងអស់អាចនឹងពិចារណាសន្សឹមៗ និងយល់ថាតាមពិតនោះយើងខ្លាចអ្វី ដរាបណាដែលយើងកើតមកយ៉ាងនេះ យើងត្រូវខ្លាច បើមិនខ្លាចអ្វីខ្លាំងទេ ក៏ខ្លាចជីងចក់ តុកកែ ខ្លាចស្រមោច ព្រោះសេចក្តីខ្លាចនៅមាននៅឡើយ ព្រោះមិនដឹងការពិតថា ខ្លាចហើយធ្វើល្អទេ? ជាមួយនឹងការមិនខ្លាច ប៉ុន្តែយល់រឿងដែលយើងខ្លាចថាជាអ្វី។

**ឌីជេ** ៖ ប្រសិនបើដូច្នេះ រឿងដែលយើងខ្លាចពិតៗនោះគឺអ្វីបាទ?

**សុចិន្ត** ៖ តាមពិតទៅ គួរនឹងខ្លាចការដែលមិនដឹងនូវការពិត ដែលខណៈនេះក៏មាន តែមិនដឹងទើបបានជាខ្លាច ទាំងដែលរបស់នោះអស់ហើយ។ យើងនិយាយរឿងរោគកូវីដ១៩ ចប់ទៅហើយ នឹងខ្លាចទៀតទេ ចប់ហើយ ឯអ្នកដែលនឹងខ្លាច ក៏ខ្លាចតទៅទៀត តែសម្រាប់អ្នកដែលមានរឿងផ្សេងៗសម្រាប់នឹកគិត គេក៏មិនគិតរឿងនេះទៀតឡើយ គ្រប់យ៉ាងគឺការខ្លាចកើត ព្រោះមិនដឹងថា តាមពិតនោះ តែមួយខណៈដែលកើតនឹងប្រាកដផ្សេងៗពីគ្នាទៅច្រើនបែបគឺអ្វី? ហេតុអ្វីកើតយ៉ាងនេះ? ហេតុអ្វី[បាន]ជាយ៉ាងនេះសម្រាប់ប្រទេសនេះ អ្នកនេះ រឿងនេះ។ គ្រប់យ៉ាងទាំងអស់ យើងមិនដឹងហេតុដែលនឹងឱ្យកើតឡើង។

ស្តាប់មើលទៅដូចជា យើងនិយាយរឿងអ្វីនេះ? តែការពិតជារឿងដែលបើគ្រប់គ្នាសាកល្បងពិចារណាក៏អាចនឹងរួចពីភាពខ្លាចបាន ដោយ[សារ]អ្វីដែលនឹងកើត រមែងកើតមែនទេ? ប្រសិនបើមិនកើត ក៏នឹងមិនមាននរណាទៅធ្វើឱ្យកើតឡើងបានឡើយ ប៉ុន្តែនឹងត្រូវមានហេតុដែលនឹងធ្វើឱ្យហេតុអ្វីរឿងនេះកើតឡើងជាមួយអ្នកនេះ ហេតុអ្វីរឿងនេះកើតឡើងជាមួយអ្នកនោះ តាមហេតុការណ៍ដែលកើតឡើងផ្សេងៗច្រើនបែបយ៉ាងណាស់។

**ឌីជេ** ៖ ខ្ញុំស្តាប់អាចារ្យសុចិន្តអធិប្បាយ ចាប់បានត្រង់ចំណុចមួយគឺ ពេលដែលយើងកើតមានសេចក្តីខ្លាចមកហើយ យើងក៏បាត់ខ្លាចទៅវិញ តែយើងអាចនឹងខ្លាចការខ្លាចពីដើមនោះកើតមកទៀត ជាការកើតរលត់ៗ យ៉ាងហ្នឹងឬទេបាទ?

**សុចិន្ត** ៖ ត្រឹមត្រូវហើយចាស។ មិនមានអ្វីដែលមិនរលត់ទៅឡើយ សូម្បីតែមួយគឺ"ការរលត់"នេះ យើងយល់ថាអស់ តែសេចក្តីពិតរបស់ដែលអស់ យើងប្រើពាក្យថា"រលត់" ព្រោះថាមិនត្រឡប់មកទៀតឡើយ ទៅស្វែងរកទីណាក៏មិនបាន ដូចជាសំឡេងអម្បិញមិញនេះ ត្រឹមតែអម្បិញមិញនេះ ឬតពីនេះ ក៏ទៅរកទីឯណាទៀតមិនបានឡើយ លឿនទេចាស? ហើយយើងក៏ភ្លេចអស់ហើយផងដែរ ហើយក៏មានសំឡេងថ្មីកើតឡើង ហើយក៏រលត់ទៅទៀត ជាយ៉ាងនេះ បិទបាំងគ្រប់ខណៈ មិនឱ្យដឹងសេចក្តីពិត។

**ឌីជេ** ៖ បើអញ្ចឹងភ័យដែលពិតប្រាកដគឺអ្វីបាទ?

**សុចិន្ត** ៖ គឺកិលេស ការមិនដឹង។ ព្រះអរហន្តលោកនឹងខ្លាចជំងឺកូវីដទេចាស?

**ឌីជេ** ៖ តាមដែលបានអានបានឮមក លោកមិនខ្លាចទេបាទ។

**សុចិន្ត** ៖ មិនមានកិលេស អស់ទៅទាំងស្រុង ព្រោះដូច្នោះ មិនញាប់ញ័រ ព្រោះដឹងដើមហេតុពិតៗថា ហេតុដែលឱ្យកើតនោះគឺអ្វី។ ប្រសិនបើមានហេតុ ហើយដល់ពេលដែលនឹងកើត នរណាក៏ឃាត់ឃាំងមិនបានឡើយ មិនថា សេចក្តីស្លាប់ បានលាភ បាត់បង់លាភ ឬមានភ័យផ្សេងៗ ឬអ្វីទាំងអស់ មិនមាននរណាទៅបញ្ជាបានឡើយ ប្រសិនបើដល់ពេលដែលនឹងកើត ក៏កើតឱ្យឃើញហើយ។

**ឌីជេ** ៖ សេចក្តីខ្លាចទាំងនេះជាភ័យយ៉ាងណាដែរបាទ?

**សុចិន្ត** ៖ ព្រោះថាយើងមិនដឹងការពិត បើនិយាយពេលនេះគឺជារឿងដែលជ្រាលជ្រៅណាស់ តែអាចនឹងយល់បាន គឺភ័យដែលយល់ខុសថា មានយើង អ្វីៗគ្រប់យ៉ាងដែលកើតឡើងជាយើង។ ប៉ុន្តែបើតាមការពិត បើដឹងពិតៗ មិនមានយើងឡើយ ធម៌ទាំងអស់ជាអនត្តា មិនមែនជាអត្តា មិនមានយើង មិនថាអ្វីទាំងអស់ ភ្លើងក៏មានបច្ច័យកើតឡើង ខ្យល់ក៏មានបច្ច័យកើតឡើង មិនថានឹងដឹងក្តៅ នឹងត្រជាក់ នឹងផ្អែម នឹងប្រៃ នឹងភ្ញាក់ផ្អើល នឹងសប្បាយចិត្តទាំងអស់នេះ មានបច្ច័យទើបកើតឡើង ប្រសិនបើមិនមានក៏មិនកើត ព្រោះដូច្នេះ យើងមិនដឹងឡើយថា របស់ទាំងនោះដែលកើតហើយរលត់ទៅវិញ មិនមែនជាយើងសូម្បីអ្វីមួយឡើយ ល្មមតែកើតមក ខណៈដែលកើតបាត់ទៅហើយ មិនត្រឡប់មកទៀតឡើយ មានតែខណៈតទៅៗរហូតដល់លាចាកលោកនេះទៅ មិនសល់ពេលណា ទើបដឹងថាតាមសេចក្តីពិតគឺមិនមានយើងតាំងតែពីកើត ព្រោះថាពេលដែលស្លាប់ក៏មិនសល់ឡើយ ដូចគ្រប់ៗខណៈ ។ ម្សិលមិញក៏មិនសល់ដល់ថ្ងៃនេះ អម្បិញមិញនេះក៏មិនសល់ដល់ឥឡូវនេះ បើមិនដូច្នោះ យើងនឹងមិនស្គាល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ឡើយ។ បានឮមួយពាក្យក៏មិនយល់ពីភាពជ្រាលជ្រៅដូចជា « **ធម៌ទាំងឡាយជាអនត្តា** » **សព្វេ** ទាំងឡាយ « **សព្វេធម្មា អនត្តា** » ផ្លាស់ប្តូរមិនបានឡើយ។ ប៉ុន្តែហេតុអ្វីយើងមិនគិតថា នេះឯងរួចពីភ័យពិតប្រាកដ។ ប្រសិនបើមានការយល់ដែលត្រឹមត្រូវ ព្រោះអ្វីដែលមាន មិនមែនយើង ល្អក៏កើតឡើងដោយមានហេតុ អាក្រក់ក៏កើតឡើងដោយមានហេតុ ផលរបស់ល្អនិងអាក្រក់ក៏កើតឡើងដោយមានហេតុ។ ហើយយើងនៅត្រង់ណា? ប្រសិនបើយើងមានពិតៗ ក៏មិនត្រូវស្លាប់មែនទេចាស? ប៉ុន្តែនេះគ្រប់គ្នាត្រូវតែស្លាប់ទាំងអស់ ហើយយើងទៅនៅណាត្រង់នោះ?

**ឌីជេ** ៖ ការរស់នៅក្នុងបច្ចុប្បន្ន មិនចាត់ថា មាននៅពិតទេឬបាទ?

**សុចិន្ត** ៖ ចាស ប្រសិនបើមិនកើតនឹងមានអត់ចាស?

**ឌីជេ** ៖ មិនមានទេបាទ។

**សុចិន្ត** ៖ ព្រោះដូច្នេះ ពេលកើតក៏មានមែនទេចាស?

**ឌីជេ** ៖ មែនបាទ។

**សុចិន្ត** ៖ ដល់ពេលដែលកើតហើយ ក៏ប្រកាន់នូវអ្វីដែលកើតឡើងថាជាយើង ប៉ុន្តែអ្វីនោះរលត់ទៅដោយយើងមិនដឹងឡើយ។ ចិត្តខណៈដំបូងដែលកើតនៅឯណា?

**ឌីជេ** ៖ តើមិនមែនជាចិត្តតែមួយនឹងចិត្តបច្ចុប្បន្នទេឬបាទ?

**សុចិន្ត** ៖ មិនមែនឡើយចាស។ ចិត្តសែនខ្លីណាស់ ។ នេះជារឿងដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់បានបំពេញបារមីយូរប៉ុណ្ណារហូតនឹងបានដឹងសច្ចៈធម៌ ការពិតដែលព្រះអង្គទ្រង់ត្រាស់ សម្តែងថា សង្ខារធម៌គឺអ្វីដែលមានបច្ច័យតាក់តែង កើតឡើងត្រូវតែរលត់ទៅ សង្ខារទាំងឡាយមិនទៀង សង្ខារទាំងឡាយជាទុក្ខ ធម្មៈទាំងឡាយជាអនត្តា បើជាអនត្តាហើយនោះមិនសល់ឡើយចាស។ តែអ្វីដែលកើតត្រូវរលត់ជាពិតប្រាកដ មិននៅអ្វីសល់ខ្លះទេ។ សាកគិត ពាក្យសម្តីអម្បិញមិញនេះ ចិត្តដែលគិតអម្បិញមិញនេះ រឹងប្រាកដ ហើយពេលដែលឃើញ រឹងបាត់ទៅណា ហើយមិនត្រឡប់មកទៀតឡើយ ប៉ះខ្ទប់ថ្មីក៏មិនមែនរឹងចាស់នោះឡើយ។

**ឌីជេ** ៖ មិនឃើញតាមអញ្ចឹងពិតមែនបាទ។

**សុចិន្ត** ៖ ចាស មិនឃើញចាស ព្រោះត្រូវស្តាប់ រហូតដល់នឹងអាចដឹងថា អ្វីដែលមានតែមួយៗ ជា ធម្មៈគឺអ្វីដែលមានពិត មិនឃើញប្រាប់ថាជាយើងឡើយ មែនទេចាស? តែប្រាប់ថាជា "ធម្មៈ" ប៉ុន្តែប្រកាន់ធម្មៈ ទាំងសភាវៈជាចិត្ត សភាវៈដែលដឹង និងរូបរាង ទាំងអស់ថាជាយើង ទាំងពីរយ៉ាងជាយើងផងដែរ។ ប៉ុន្តែត្រង់ណាដែលជារបស់យើងបាន? បង្គាប់បញ្ជាមិនបានឡើយ មិនចង់ឱ្យឈឺចុកចាប់ ហើយហេតុអ្វីបានជាឈឺក្បាលជង្គង់ ហើយយ៉ាងម៉េច ណាទៅរបស់យើង? របស់យើងអម្បិញមិញនេះមិនឈឺ ហើយពេលនេះឈឺមកពីណា? ក្លាយជាយើងឈឺទៅទៀតហើយ ដល់ពេលព្យាបាលជា ពេលឈឺដែលថាជារបស់យើងនោះបាត់ទៅណា? ដែលថាជាយើងបាត់ទៅទាំងអស់ តែមួយៗ។ ឃើញអម្បិញមិញនេះដែលជាយើង ដល់ពេលមិនឃើញ យើងដែលឃើញអម្បិញមិញនេះបាត់ទៅណា? ជារឿងដែលល្អិតល្អន់ ព្រោះដូច្នេះ ការស្តាប់ព្រះធម៌ត្រូវតែដឹងថា ជារឿងដែលល្អិតល្អន់ជ្រាល

ជ្រៅ បើសិនយល់ពិតៗ នឹងមិនញាប់ញ័រ ព្រោះជាហេតុដែលនាំឱ្យធ្វើតែរឿងដែលល្អ ដើម្បីផលដែលល្អនឹងកើតឡើង មិនមែនផលដែលមិនល្អឡើយ។

**ឌីជេ** ៖ ពេលដែលយើងឈឺ ពេលដែលយើងសុខ ពេលដែលយើងខ្លាច ពេលដែលយើងខឹង ឬ ពេលដែលមានអារម្មណ៍ទាំងឡាយប្រាកដក៏ដោយ យើងមានអារម្មណ៍ថា វាឈឺពិត វាទុក្ខពិត ហើយយើងនឹងចាត់ការជាមួយនឹងវាយ៉ាងដូចម្តេច បាទ?

**សុចិន្ត** ៖ កុំទាន់ទៅចាត់ការអីណា ចាស យើងឈឺមែនទេ ចាស?

**ឌីជេ** ៖ បាទ។

**សុចិន្ត** ៖ ប្រសិនបើឈឺមិនកើតទេ នឹងមានយើងឈឺទេ?

**ឌីជេ** ៖ មិនមានទេ បាទ។

**សុចិន្ត** ៖ ចាស លោកគង់តែមិនឈឺរហូតគ្រប់ពេលវេលាមែនទេ ចាស?

**ឌីជេ** ៖ ប៉ុន្តែដូចជានៅពេលដែលឈឺធ្មេញ ក៏ឈឺយូររហូតដូចគ្នា បាទ។

**សុចិន្ត** ៖ ព្រោះដូច្នោះ យើងគិតថាយូរ តែតាមសេចក្តីពិត ការឈឺកើតហើយរលត់ កើតហើយរលត់ កើតហើយរលត់ កើតហើយរលត់ មិនប្តូរទើបធ្វើឱ្យប្រាកដថាយូរ បើសិនជានៅឈឺដល់ពេលនេះ ទៅរួចទេ ចាស? បើសិនជានៅមានបច្ច័យក៏អាចទៅបាន តែបើទៅរកពេទ្យដកធ្មេញចេញ នៅឈឺទៀតឬទេ? ឃើញទេ ចាស ពេលដែលឈឺកើតឡើង មិនដឹងការពិតថា យើងមិនបានទៅធ្វើឲ្យឈឺកើត ប៉ុន្តែមានហេតុដែលឈឺកើត ប៉ុន្តែនៅពេលដែលកើតហើយ ជាយើងឈឺ យើងកំពុងចាំបាន រឿងនេះក៏ចាំបាន រឿងនោះក៏ចាំបាន ប៉ុន្តែមិនដឹងទេថា ចាំក៏មិនមែនយើង ប៉ុន្តែបើមិនមានចាំ ក៏មិនមានយើងចាំ ប៉ុន្តែនៅពេលមានចាំក៏ជាយើងចាំ ទាំងអស់ដែលមាន ប្រកាន់ថា ជាយើង ដោយអវិជ្ជា ការមិនដឹង។ បើដឹងពិតៗ ដឹងតាមសេចក្តីពិតថា តែមួយខណៈៗ តែមួយៗ ប្រាកដឲ្យដឹងថាមានពិត អ្វីនោះត្រូវតែកើតដោយមិនមានយើងទៅធ្វើឲ្យកើត កើតហើយ ក៏ត្រូវរលត់ទៅ ប៉ុន្តែតគ្នាលឿនបំផុត ដែលនឹងប្រមាណបានដូចពន្លឺភ្លើង ដែលនៅកំពុងភ្លឺ គ្រប់ពេលវេលា ព្រោះយើងមិនដឹងថា តាមពិតទៅតែមួយ ភ្លាមៗដែលរលត់ អ្វីដទៃក៏កើតផ្ទួនគ្នាភ្លាមៗ មិនប្រាកដការរលត់របស់ដែលចាស់នោះ ។ ព្រោះដូច្នោះការមិនដឹងក៏បោកប្រាស់ឲ្យឃើញជារូបរាងសណ្ឋាន បិទភ្នែកមើល ចាស មានទេ ចាស ?

**ឪជេ** ៖ មិនឃើញទេ បាទ។

**សុចិន្ត** ៖ បើកភ្នែកទៅ ចាស ។

**ឪជេ** ៖ ឃើញ បាទ។

**សុចិន្ត** ៖ ឃើញទេ ចាស? ហើយចុះអ្វីជារបស់ដែលប្រាកដផ្លូវភ្នែក ក៏ត្រឹមតែប្រាកដ ប៉ុន្តែចាំទុកទាំងអស់ ជាមនុស្ស ជាផ្កា ជាដើមឈើ ជាអ្វីគ្រប់យ៉ាង ត្រឹមតែបិទភ្នែក មិនមានរបស់ទាំងនោះទៀតឡើយ នរណាក៏ទៅធ្វើឲ្យមានមិនបានឡើយ។ គ្រាន់តែ ប៉ុណ្ណេះ ក៏មិនដឹងហើយថា ព្រោះរលត់ ហើយពេលបើកភ្នែកជាថ្មី ហើយមិនដូច ដែលមុនរលត់ ជាខណៈថ្មីមិនមែនខណៈចាស់។ ព្រោះដូច្នោះ ជីវិតក៏តាំងនៅត្រឹមតែ ១ខណៈ កើតរលត់ទៅរឿយៗ។ ព្រោះដូច្នោះ សេចក្តីស្លាប់ ទ្រង់សម្តែងទុកមាន ៣យ៉ាង ខណិកមរណៈ ខណិកៈមកពី ពាក្យថា ខណៈ ខណិកមរណៈ ស្លាប់គ្រប់ខណៈ ព្រោះអ្វីដែលប្រាកដពេលនេះ រលត់ហើយមិនត្រឡប់មកទៀតឡើយ មិនថាអ្វីគ្រប់យ៉ាង តែលឿនរហូតដល់គ្មានអ្នកទៅដឹង ក៏ដូចនៅស្ថិតថេររហូតគ្រប់ពេល។ សម្មតិមរណៈ សន្មតថាស្លាប់ ក៏គឺពេលដែលដាក់ចុះក្នុងមឈូស ទៅផុតអស់អាយុហើយ គឺសន្មត មិនមែនដល់ទីបំផុតពិតនោះទេ។ ព្រោះហេតុថា ស្លាប់ហើយក៏កើតភ្លាមមួយរំពេច នេះ គ្មាននរណាដឹងឡើយ ក្រៅតែពីព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែង នៃការកើតឡើង របស់ចិត្តដែលកើតរលត់តគ្នា ដោយល្អិតល្អន់យ៉ាងក្រៃលែងថា តែមួយខណៈនោះខុសគ្នា ដូចម្តេច កើតឡើងបានដោយសារអ្វី ប្រកបជាមួយអ្វីខ្លះ ច្រើនយ៉ាងណាស់។ ប៉ុន្តែសូម្បី តែខណៈនេះកំពុងកើតរលត់ដូចស្លាប់ ប៉ុន្តែក្នុងមួយខណៈក៏កើតទៀត ក៏ជា ខណិកមរណៈ ប៉ុន្តែសម្មតិមរណៈ ដែលដឹងតាមគ្នាមកថាស្លាប់ពិតៗ ក៏នាំទៅផុត និងសមុច្ឆេទមរណៈ គឺការបរិនិព្វាន ឬ ការស្លាប់របស់ព្រះអរហន្ត ដែលមិនមានការកើត តទៅទៀតឡើយ បើមិនដូច្នោះទេ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ក៏ត្រូវស្ថិតនៅមែនទេ ចាស ? កើតតទៅទៀតទេ? ប៉ុន្តែនេះមិនមានឡើយ។ ព្រះសាវ័ក ដែលជាព្រះអរហន្តទាំងឡាយ ដល់ពេលក៏បរិនិព្វាន គឺនៅពេលចិត្តចុងក្រោយរលត់ មិនមានការកើតតទៅទៀតឡើយ។ ប៉ុន្តែសម្រាប់អ្នកផ្សេង ទាំងអស់ ក្រៅពីព្រះអរហន្ត ដែលនៅមានកិលេសដែលនៅមិនទាន់រលត់អស់ ក៏ជាបច្ច័យ ឲ្យពេលដែលស្លាប់ហើយកើតភ្លាម។ ទ្រង់សម្តែងទុកទាំងអស់ គ្រប់យ៉ាង តែយើងមិនដឹង យើងក៏ប្រកាន់ថា កើតជាយើងទៅរឿយៗ ហើយក៏ស្លាប់ ប៉ុន្តែបានដឹងអត់ថា ជាតិនេះជា ជាតិមុនរបស់ជាតិខាងមុខ ដល់ពេលជាតិមុខ មិនដឹងសោះថា ជាអ្នកនេះ ធ្លាប់ធ្វើយ៉ាងនេះ

យ៉ាងនោះ ព្រោះថាជាអ្នកថ្មី ដូចដែលខណៈនេះ យើងក៏មិនដឹង សោះថា ជាតិមុននរណា ជា ឪពុកម្ដាយ បងប្អូន មិត្តភ័ក្តិ ធ្វើអ្វីខ្លះ សប្បាយរីករាយយ៉ាងណា ក៏នឹងជាអ្នកនេះ នៅបាន ត្រឹមតែខណៈដែលមិនស្លាប់ ប៉ុន្តែនៅពេលដែលស្លាប់ ក៏អស់សភាពជាបុគ្គលនេះ រកទៀត មិនបានឡើយ នៅក្នុងសង្សារវដ្ត។

**ឌីជេ** ៖ ព្រះអរហន្តលោកចែកភាពតគ្នាដែលល្អិតល្អន់នោះបានទេ បាទ?

**សុចិន្ត** ៖ ប្រសិនបើមិនប្រច័ក្ស សច្ចធម៌ ដែលជាអរិយសច្ច៤ រំលត់កិលេស មិនបានស្តាប់ ប៉ុណ្ណា យល់ប៉ុណ្ណា ប៉ុន្តែនៅមិនប្រច័ក្សច្បាស់សភាវធម៌ ដែលជាយ៉ាងនោះពិតៗ ក៏រលត់ កិលេសមិនបានឡើយ ព្រោះកិលេស មានច្រើនលំដាប់ តាំងតែពីគ្រោតគ្រោត ប្រាកដឲ្យ ដឹងបាន យ៉ាងកណ្តាល និងយ៉ាងល្អិតដែលដេកសង្ងំក៏មាន តែមិនប្រាកដ។ ព្រោះដូច្នោះ ព្រះអរហន្តលោកសម្រាន្តលក់ជាមួយនឹងចោរដេក មិនមាននរណាដឹងសេចក្តី ផ្សេងគ្នា ឡើយ។ តែសភាពរបស់ចិត្តផ្សេងគ្នា ព្រោះដូច្នោះ ក៏ជារឿង ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងការពិតដល់ទីបំផុត ពិសោធន៍បាន ហេតុអ្វីអ្នកនេះមិនកើតរោគនេះ ហេតុអ្វីអ្នកផ្សេងកើត ជ្រើសរើសបានទេ ចាស?

**ឌីជេ** ៖ មិនបានទេ បាទ។

**សុចិន្ត** ៖ ចាស ក៏សម្តែងច្បាស់លាស់ថា "អនត្តា" មិនស្ថិតនៅក្រោមបង្គាប់បញ្ជា របស់នរណាឡើយ ព្រោះដូច្នោះ ពាក្យថា "អនត្តា" ក៏មានន័យថាមិនមែនយើង និងមិនមាន យើង ព្រោះហេតុថា មានតែធម្មៈ ដែលកើតរលត់ ផ្លាស់ប្តូរគ្រប់ពេល វេលារហូតដល់ទីបំផុត ក្នុងមួយជាតិ ក៏ដូចដែល នៅក្នុងជាតក ដែលទ្រង់សម្តែង ព្រះជាតិផ្សេងៗរបស់ព្រះអង្គ មុនពេលដែលបានត្រាស់ដឹង។

**ឌីជេ** ៖ ការពិតដែលអាចារ្យសុចិន្តនិយាយដល់នេះ ដែលប្រាប់ថា ព្រោះយើងមិនដឹង សេចក្តីពិត ការពិតដែលថានោះគឺអ្វី បាទ?

**សុចិន្ត** ៖ ឥឡូវនេះអ្វីពិត ចាស? "ឃើញ"ពិតឬទេ ចាស?

**ឌីជេ** ៖ ឃើញ?

**សុចិន្ត** ៖ ពិតឬទេ ចាស? កំពុងឃើញឬទេ?

**ឌីជេ** ៖ កំពុងឃើញ បាទ។

**សុចិន្ត** ៖ មានភ្នែក តែមិនមានអ្វីមកប៉ះខ្ទប់នឹងភ្នែក នឹងឃើញឬទេ ចាស?

**ឌីជេ** ៖ មិនឃើញទេ បាទ។

**សុចិន្ត** ៖ ចាស ព្រោះដូច្នោះ កំពុងឃើញត្រូវកើត ប្រសិនបើមិនមានភ្នែកឃើញបានទេ?

**ឌីជេ** ៖ មិនឃើញទេ បាទ។

**សុចិន្ត** ៖ ព្រោះដូច្នោះ ឃើញតែចំពោះរបស់ដែលប៉ះខ្ទប់នឹងភ្នែកបានប៉ុណ្ណោះឯង ត្រឹមត្រូវទេ ចាស?

**ឌីជេ** ៖ ពេលដែលមិនគ្រប់បច្ច័យមិនឃើញ។

**សុចិន្ត** ៖ នៅត្រង់ដៃក៏មិនមានភ្នែក ការឃើញក៏មិនបាននៅត្រង់ដៃ ប៉ុន្តែនៅត្រង់ភ្នែក យើងមិនអាចនឹងឃើញរូបរបស់រូបដែលអាចប៉ះខ្ទប់នឹងភ្នែកបាន គឺត្រូវមានភ្នែក និងមានរបស់ដែលកំពុងប៉ះខ្ទប់ភ្នែកផងដែរ ដែលឃើញរបស់នោះត្រូវតែប៉ះខ្ទប់ភ្នែក។ ប៉ុន្តែនៅណា ចាស? ប្រសិនបើព្រះពុទ្ធជាម្ចាស់មិនត្រាស់សម្តែង រកមិនជួប ដឹងតែត្រឹមកំពុងឃើញរបស់នោះ តែរបស់នោះនៅឯណា?

**ឌីជេ** ៖ មិនមែនរបស់យើង ហើយយើងស្រវ៉ាចាប់ វាបានត្រង់នោះឬ បាទ?

**សុចិន្ត** ៖ ពេលដែលចាប់នោះ ចាប់អ្វី ចាស?

**ឌីជេ** ៖ ចាប់វត្ថុដែលយើងឃើញ។

**សុចិន្ត** ៖ រឹងមែនទេ ចាស?

**ឌីជេ** ៖ រឹងក៏មាន បាទ។

**សុចិន្ត** ៖ ចាស ចាប់របស់ដែលកំពុងប្រាកដផ្លូវភ្នែកបានទេ?

**ឌីជេ** ៖ ចាប់របស់ដែលកំពុងប្រាកដផ្លូវភ្នែក ចាប់អត់បានទេ បាទ។

**សុចិន្ត** ៖ នេះក៏ចែកពីគ្នាហើយ ប៉ុន្តែរបស់ដែលប្រាកដតាមផ្លូវភ្នែក នៅឯកន្លែងដែលរឹង តែមិនមែនរឹង បើសិនមិនមានធាតុដី ទឹក ភ្លើង ខ្យល់ ត្រជាក់ ក្តៅ ទន់ រឹង ជាដើម នឹងមិនមានរបស់ដែលប៉ះខ្ទប់ភ្នែកបានឡើយ ប៉ុន្តែរបស់ដែលប៉ះខ្ទប់ភ្នែកបាន ហើយធ្វើឲ្យការឃើញ ឬចិត្តឃើញ សភាវៈដែលដឹងកើតឡើង ឃើញហើយរលត់ទៅ មិនសេសសល់ឡើយ។ គិតក៏មិនបាន អ្វីក៏មិនបាន ត្រឹមតែនឹងឃើញ ព្រោះកម្មជាបច្ច័យឲ្យកើតហើយ

ត្រូវឃើញ ត្រូវឮ ត្រូវបានដឹងក្លិន ត្រូវបានដឹងរស ត្រូវដឹងអ្វីដែលប៉ះខ្ទប់សម្ផស្ស មានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ដើម្បីទទួលផលរបស់កម្ម។

**ឌីជេ** ៖ បើដូច្នោះរបស់ដែលខ្ញុំចាប់ហើយរឹង វាមានអត់ទេ បាទ?

**សុចិន្ត** ៖ ចាប់ហើយត្រូវតែរឹង ពិតប្រាកដ ចាស ឬក៏ទន់ ឬក៏ត្រជាក់ ឬអត់ទេក៏ក្តៅ ឬអត់ទេក៏តឹង ឬអត់ទេក៏ញ័រ មែនទេ ចាស? ទឹក ត្រជាក់ឬក្តៅ ទន់ឬរឹង តឹងឬញ័រ? ប៉ុន្តែយើងសន្មតថាទឹក។ ទាំងអស់មានតែការពិតទេដែលអាចពិសោធន៍បាន ប៉ុន្តែត្រូវតែមាំទាំគង់វង្ស ដែលនឹងជាបុគ្គលត្រង់ ដែលនឹងយល់សន្សឹមៗនូវការពិតថា របស់ដែលកំពុងប្រាកដតាមផ្លូវភ្នែកឱ្យឃើញនេះ នោះវាមិនមែនរឹង ប៉ុន្តែវានៅត្រង់កន្លែងដែលរឹង ត្រង់ធាតុដី ទឹក ភ្លើង ខ្យល់ សម្តែងទុកយ៉ាងល្អិតល្អន់ថា ត្រង់នោះមានកលាបរូបជាច្រើនបែបផ្សេងគ្នា ប៉ុន្មានប្រភេទ ដែលញែកឲ្យចេញពីគ្នាមិនបានឡើយ ទៅញែកពណ៌ វណ្ណៈ ដែលប៉ះខ្ទប់នឹងភ្នែក ឲ្យចេញពីរឹង ក៏មិនបានឡើយ ផ្កាក៏រឹង កៅអីក៏រឹង កាសែតក៏រឹងតែរឹងមិនបានប៉ះខ្ទប់ភ្នែក ប៉ុន្តែរបស់ដែលនៅត្រង់រឹង ជារូបពណ៌ វណ្ណៈ ជារូបផ្សេងទៀតដែលមិនមែនរឹង ប៉ុន្តែនៅត្រង់រឹង។ ទ្រង់សម្តែងទុក ល្អិតល្អន់ណាស់ ដល់ក្នុងជីវិតប្រចាំថ្ងៃក្នុងមួយខណៈៗ បើកបង្ហាញរហូតឲ្យដឹងថា ជារបស់ដែលមានពិត ព្រោះដូច្នោះ ធម្មៈ គឺជាអ្វីដែលមានពិត ព្រះអង្គទ្រង់សម្តែង នូវអ្វីដែលមានពិតនោះ ទើបប្រើពាក្យត្រាស់ដឹងនូវធម៌ គ្រប់យ៉ាងដែលពិតគឺជាធម្មៈទាំងអស់ និងត្រាស់ដឹងផងដែរ។

**ឌីជេ** ៖ អ្វីដែលអាចារ្យសុចិន្តអធិប្បាយ ខ្ញុំនឹកតាមហើយក៏អាចនឹងយល់បានចំណុចខ្លះ ហើយមានអារម្មណ៍ថាច្របូកច្របល់ ល្អិតល្អន់ណាស់ ធ្វើយ៉ាងណាទើបយល់នូវរឿងនេះបានពិតៗ បាទ?

**សុចិន្ត** ៖ ចាប់ផ្តើមស្គាល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ហើយមែនទេ ចាស? ពាក្យពិតយ៉ាងនេះ ដែលសម្តែងដល់របស់ដែលមានពិត តើនរណាអាចសម្តែងបាន ហើយល្អិតល្អន់ជាងនេះទៅទៀត? ច្រើនណាស់ នេះត្រឹមតែមិនប៉ុន្មានពាក្យប៉ុណ្ណោះ ប៉ុន្តែទ្រង់សម្តែងទៅដល់ ៨៥វស្សា មួយពាក្យៗ ជ្រាលជ្រៅខ្លាំងណាស់ សូម្បីតែពាក្យថា "ធម្មៈ" នរណានឹងដឹងថាមានន័យថា គ្រប់យ៉ាងដែលមានពិត ច្រើនបែបណាស់ ហើយប្រមូលមកហៅថា"ធម្មៈ" គឺរបស់ដែលមានពិត ភាសាថៃប្រើពាក្យថា "របស់ដែលមានពិត" ប្រសិនបើទៅ និយាយនៅឯប្រទេសផ្សេងទៀត ដូចជា ឥណ្ឌា គេក៏មិនដឹងថាមានន័យដូចម្តេច ព្រោះដូច្នោះ ភាសាដែលព្រះអង្គត្រាស់ក្នុងការសម្តែងការពិត ក៏ប្រើពាក្យថា "ធម្មៈ"។ការបញ្ចេញសំឡេង

តាមត្រឹមត្រូវផងណា ចាស ប៉ុន្តែជនជាតិថៃបញ្ចេញសំឡេងភាសាបាលីមិនចំ ប៉ុន្តែក៏អាច យល់បានសម្រាប់ជនជាតិថៃ ប៉ុន្តែបើសិនជាសកលលោក គេនឹងមិនដឹង ព្រោះ យើង បញ្ចេញសំឡេងមិនត្រឹមត្រូវ ដូចជា"ធម្មៈ" យ៉ាងនេះ dh ភាសាថៃយើងក៏ ធម្មៈ ។

**ឌីជេ** ៖ យើងបញ្ចេញសំឡេងជា .ធ. សំឡេង ធឺៈ បាទ ។

**សុចិន្ត** ៖ ក៏អញ្ចឹងឯង ចាស ភាសាឬសំឡេងដែលចង្អុលឱ្យដឹងថាមានន័យថាដូចម្ដេច សម្គាល់នៅក្នុងភាសារបស់ខ្លួន រៀងៗខ្លួន ព្រោះដូច្នោះ យើងនឹងមិនខ្វល់ខ្វាយថា នឹង និយាយបញ្ចិតបញ្ចៀង និយាយខុសទៅខ្លះ សូមឲ្យបានយល់ថា មានន័យដូចម្ដេច ព្រោះ ដូច្នោះ អ្វីដែលសំខាន់បំផុតនោះគឺ ការដែលយល់ត្រឹមត្រូវ ដោយហេតុនេះ ភាសាមគធៈ ដែលប្រើជាភាសាទ្រទ្រង់ព្រះពុទ្ធសាសនា គឺបាល ឬបាលី ក៏គឺ"ធម្មៈ" មានន័យ ថាអ្វីដែល មានពិត គ្រប់យ៉ាងជា"ធម្មៈ" ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ដឹងការពិត នូវរបស់ដែលមានពិត ទៅតាមសេចក្ដីពិតនៃរបស់នោះ ដូចជាឃើញ មិនមាននរណា ទៅចាប់កាន់"ឃើញ"បានឡើយ ឃើញកើតឡើងដឹង តែមិនដឹងដទៃឡើយ ដឹងថាអ្វីដែល កំពុងប្រាកដពេលនេះជាយ៉ាងនេះ ចំពោះប៉ុណ្ណោះឯង ហើយរលត់ ហើយមិន ត្រឡប់មក ទៀត ធ្វើយ៉ាងផ្សេងក៏មិនបាន បើពេលបានឮ មិនមែនឃើញឡើយ ចាស ដឹងតែចំពោះ សំឡេងដែលកំពុងប៉ះខ្ទប់ត្រចៀក មិនមែនសំឡេងដទៃ ហើយក៏រលត់ទៅ ។

នេះគឺជាអ្វីដែលទ្រង់សម្ដែងថា ធម្មៈទាំងឡាយ មិនមែនខ្លួន មិនមែនសត្វ មិនមែនបុគ្គល ជាអនត្តា មិនស្ថិតនូវក្រោមអំណាចបង្គាប់បញ្ជារបស់នរណា ពិសោធន៍បាន ដូចជា រោគកូវីដ-១៩ ស្ថិតនូវក្រោមអំណាចបង្គាប់បញ្ជារបស់នរណា? ប៉ុន្តែយើងមិនដឹងថា ការពិតនោះៗគឺអ្វី ប្រសិនជាមិនបានឮ មនុស្សថ្លង់ ពិការភ្នែក នឹងអាចដឹងបានទេថា យើងកំពុងតែនិយាយរឿងអ្វី គេក៏មិនមានការដឹង ការយល់ក្នុងរឿងនេះឡើយ ព្រោះដូច្នោះ តែមួយៗ គឺជាលោកមួយៗដែររួមគ្នា ច្របូកច្របល់ រហូតដល់ទៅជាលោកដែលពេញ ទៅដោយរូបផ្សេងៗ សំឡេងផ្សេងៗ ក្លិនផ្សេងៗ រសផ្សេងៗ ធ្វើឲ្យនឹកគិតថារឿងរ៉ាវផ្សេងៗ ទ្រង់សម្ដែងដល់ភាវៈ ដែលធាតុដឹងនោះប្រកបផ្សំដោយសភាពអ្វីខ្លះ ដែលមាននាទី ច្រើនយ៉ាង ដូចជាចាំក៏ជាអ្វីដែលមានពិតប៉ុន្តែក៏មិនមែនជាយើង ហើយតើនឹងទៅចាំអ្វី ក្រៅពីអ្វីដែលប្រាកដ ប្រសិនបើមិនឃើញសោះឡើយ នឹងចាំបានទេ ? មិនបានឮសោះ ឡើយ ចាំបានទេ? នេះគឺជារឿងរបស់ជីវិតទាំងអស់ដែលកើតមក ប្រសិនបើបានដឹង

បានយល់ថាជារឿងយ៉ាងនេះឯង គ្រប់ជាតិដូចៗគ្នាទាំងអស់ ជាសង្សារវដ្ត ដែលមិនចេះចប់ឡើយ នឹងយល់ខុសថាជាយើង ប៉ុន្តែជាធម្មៈ ចាស ។

**ឌីជេ** ៖ ខ្ញុំសូមអនុញ្ញាតយកឧទាហរណ៍ដែលទើបតែជួបមកមិនយូរប៉ុន្មាននេះឡើយ ជារឿងរបស់មិត្តភក្តិខ្ញុំម្នាក់ ដែលខកបំណងពីសេចក្តីស្រលាញ់ អ្នកដែលគាត់ មានអារម្មណ៍ថាគាត់ស្រលាញ់ខ្លាំងណាស់ មិនស្រលាញ់គាត់ដូចដើមឡើយ និងមិនចង់នៅជាមួយគាត់ទៀតឡើយ។ គាត់មានសេចក្តីទុក្ខណាស់ ទុក្ខដល់ ថារឿងផ្សេងៗ មិនមានន័យអ្វីឡើយ។ សម្រាប់អ្នកដែលនៅក្នុងហេតុការណ៍បែបនេះ ធ្វើដូចម្តេចទើបអាចយល់ ឬអាចរួចផុតពីសេចក្តីទុក្ខនោះបាន បាទ ?

**សុចិន្ត** ៖ គាត់មិនដឹងឡើយថា ប្រសិនបើគាត់មិនធ្លាប់ឃើញម្នាក់នោះ សេចក្តីស្រលាញ់នេះនឹងមានទេ ?

**ឌីជេ** ៖ មិនមានទេ បាទ ។

**សុចិន្ត** ៖ ប៉ុន្តែព្រោះឃើញមែនទេ ?

**ឌីជេ** ៖ មែនហើយបាទ ។

**សុចិន្ត** ៖ ប៉ុន្តែគេមិនដឹងថា ឃើញនោះរលត់ហើយ ព្រោះដូច្នោះ អ្វីដែលគាត់មាន គឺសេចក្តីស្រលាញ់ ស្រលាញ់នូវរបស់ដែលមិនសល់ឡើយ អស់ហើយ ប៉ុន្តែព្រោះការ មិនដឹងទើបយល់ថានៅកំពុងមាន នេះព្រោះនៅវង្វេងថារបស់នោះគង់នៅ ទើបជាហេតុឲ្យ ជាប់ជំពាក់ស្អិតណែន ព្រោះដូច្នោះការដែលជាប់ជំពាក់មានពិត។ នរណាមិនមាន? ព្រះសោតាបន្នក៏នៅមាននៅឡើយ ចាស ព្រះអនាគាមីបុគ្គលមួយលំដាប់ទៀតរហូត ដល់ថ្នាក់ព្រះអរហន្តប៉ុណ្ណោះ ដែលមិនមានការជាប់ជំពាក់ ។ ព្រោះដូច្នោះ កិលេសតែមួយ យ៉ាងៗ ទំរាំតែរលត់បាន មិនមែនថាយើងធ្វើដូចម្តេចនឹងជាយ៉ាងណាឡើយ ប៉ុន្តែ ការមិនដឹងនាំមកនូវកិលេសទាំងឡាយ កិលេសគ្រប់ប្រភេទ ការសម្គាល់ខ្លួន ការស្រឡាញ់ខ្លួន ការចង់បាត់ទុក្ខសោកទាំងអស់ ព្រោះមិនដឹងថាហេតុមកពីអ្វី ប្រសិនបើមិនរលត់ហេតុ នឹងអាចទៅរួចទេដែលចង់ឲ្យអ្វីនោះមិនមាន ដូចដែលមិនមានយើងពិតៗក៏ដឹង ប៉ុន្តែថាយើងទៅពេញចិត្ត ជាប់ជំពាក់ ព្រោះមិនប្រាកដការកើតរលត់ ប៉ុន្តែបើសិនជាប្រាកដការកើតរលត់ ត្រឹមតែជាព្រះសោតាបន្ន ក៏នៅមិនអាចលះបង់ សេចក្តីស្រលាញ់ ការជាប់ជំពាក់ សេចក្តីត្រូវការការដែលប្រកាន់ដែលសន្សំមកយូរសែនយូរនៅក្នុងសង្សារវដ្ត ប្រសិនបើបានដឹងថា ទំរាំតែ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ នឹងបានត្រាស់ដឹងថាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់កើតជាព្រះពោធិសត្វយូរប៉ុណ្ណា សូម្បីតែ នឹងបានទទួលពាក្យព្យាករណ៍ ពីព្រះពុទ្ធជាម្ចាស់មួយព្រះអង្គ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ព្រះនាមថាទីបង្ករថា សុមេធតាបស នឹងបានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គនេះ ៤អសង្ខេយ្យ ១សែនកប្ប នឹងបានត្រាស់ដឹងនូវអ្វីដែលយើងកំពុងបានស្តាប់ ក៏នឹងឃើញ បានថា ដរាបណាមិនមែនជាការដឹងពិតៗ អរិយសច្ចៈ។ ទុក្ខអរិយសច្ចៈ បានដល់ទុក្ខ ដែលកើតឡើងហើយរលត់ទៅ ប្រសិនបើមិនប្រច័ក្សយ៉ាងនេះក៏នៅជាប់ជំពាក់ ស្តាប់ប៉ុណ្ណា ក៏អ្វីនោះនៅគង់មានយូរអង្វែងហើយ ទៅប្រាប់គេថាមិនឲ្យទៅជាប់ជំពាក់ ដោយបានយ៉ាងម៉េចព្រោះគេមិនបានដឹងការពិត ។

**ឱជេ** ៖ មិនអាចធ្វើអ្វីបានទេ។

**សុចិន្ត** ៖ ប៉ុន្តែបើមិនចាប់ផ្តើមយល់សោះឡើយតាំងពីថ្ងៃនេះ ពេលណានឹងដល់ថ្ងៃនោះលំបាកបំផុត មិនមាននរណាដែលបានដល់នូវការយល់ព្រះពុទ្ធសាសនា ហើយនឹងប្រាប់ថាមិនលំបាក មិនជ្រាលជ្រៅឡើយ។ ព្រោះដូច្នោះ ព្រះពោធិសត្វបំពេញព្រះបារមីរហូតដល់ភាពជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះគុណរបស់ព្រះធម៌តែមួយពាក្យ ដែលធ្វើឲ្យយើងបានយល់ដល់នូវអ្វីដែលនៅក្នុងភាពងងឹតឈឹង ឲ្យឃើញយ៉ាងណា ក៏មិនបាន ឃើញការពិតរបស់អ្វីនោះ បានយល់ត្រឹមត្រូវតាមសេចក្តីពិត។ រហូតដល់នៅពេលនោះ មានអ្នកដឹងនូវអរិយសច្ចធម៌ជាព្រះអរហន្តក៏ច្រើន បើសិនជាមិនទាន់ដល់លំដាប់នោះទេ ក៏ជាព្រះអានាគាមី ជាព្រះសកទាគាមី ជាព្រះសោតាបន្ន ឬជាកល្យាណបុថុជ្ជន ទោះបីជានៅមានកិលេស ប៉ុន្តែក៏នៅមានគុណគឺសេចក្តីល្អ ដែលបានយល់ព្រះធម៌ ដែលនឹងនាំទៅការរំលត់កិលេសបាន។

ព្រះធម៌នៅមាន ចាស ប៉ុន្តែផ្លូវដែលនឹងបានដល់លំដាប់ដែលលោកឱជេត្រូវការ គឺឲ្យគេរួចផុតពីទុក្ខ មិនឲ្យមានការស្រលាញ់ ការជាប់ជំពាក់ ត្រូវតែជាបញ្ញាលំដាប់ ដែលដល់ជាព្រះអានាគាមីបុគ្គល។ នាងវិសាខាមិគារមាតា ដែលលោកជាឯតទគ្គផ្នែកឲ្យទានឧបាសិកាលោកក៏មានគ្រួសារ មានកូន មានចៅ ព្រោះកិលេសរំលត់ភ្លាមៗ មិនបានឡើយ ត្រូវរលត់ការមិនដឹងដែលកើតព្រមជាមួយការយល់ខុស ដែលប្រកាន់ថាជា យើង។ ព្រោះហេតុដូច្នោះ រឿងខ្លះដែលយើងដឹងថា មិនមែនជារបស់ពិត ក៏នៅតែជាទីពេញចិត្តបាន។ ពេជ្រ អ្នកខ្លះក៏ចូលចិត្តត្បូងក្លែងក្លាយ ពេលខ្លះក៏ដូចពិត នឹងមិនចូលចិត្តបានយ៉ាងម៉េចទៅបើវាដូចយ៉ាងនោះ។ ប៉ុន្តែដឹងឬទេ? មិនពិតក៏នៅ ចូលចិត្ត ដូចដែលបានដឹងអរិយសច្ចធម៌

ហើយ ប៉ុន្តែកិលេសដែលសន្សំមកច្រើនអនេកមហាសាល នៅមិនអាចលះការប្រកាន់បាន។ ព្រោះដូច្នោះ នរណានឹងរួចពីទុក្ខ ព្រោះសេចក្ដីស្រឡាញ់ ព្រោះការជាប់ជំពាក់ ព្រោះនៅមានអ្វីស្ថិតនៅ ក៏តាមហ្នឹងឯង។ ក៏ត្រូវមានបញ្ញាដល់លំដាប់នោះ ចាស។ ព្រោះដូច្នោះ នឹងជួយគាត់ឲ្យគាត់ ឱ្យយល់នូវ ការពិត សន្សឹមៗ បើសិនគាត់ចង់រួចផុតទុក្ខ ឬនរណាក៏ដោយ ដែលចង់ដឹងការពិត សូម្បីតែនៅមិនទាន់ចង់រំលត់ មិនមានការកើតទៀត ប៉ុន្តែត្រូវឲ្យយល់ការពិតថា អ្វីត្រូវ អ្វីខុស ក៏នឹងជួយឲ្យជីវិតប្រព្រឹត្តទៅនៅក្នុងផ្លូវស្រស់ស្អាត មិននាំមកនូវសេចក្ដីទុក្ខ ដល់ខ្លួនឯង និងបុគ្គលដទៃ។ ព្រោះដូច្នោះពិភពលោកនឹងនៅសប្បាយជាងនេះ ប្រសិន បើមិនមានទុច្ចរិត សូម្បីមានជំងឺកាចសាហាវផ្សេងៗកំពុងបៀតបៀននៅឡើយ ប៉ុន្តែចិត្ត ដែលមាំទាំគង់វង្សមិនញាប់ញ័រ និងជួយយកអាសាគ្នាមើលថែគ្នានឹងគ្នា ក៏នឹងធ្វើឲ្យគ្រប់យ៉ាងល្អឡើងតាមសមគួរដល់ហេតុ។

**ឌីជេ** ៖ តើធ្វើដូចម្ដេចឲ្យអ្នកដែលកំពុងស្ថិតនៅក្នុងសេចក្ដីទុក្ខ បើកចិត្តមកស្ដាប់រឿងទាំងនេះ បាទ?

**សុចិន្ត** ៖ ត្រូវប្រាប់គេ និងមើលថាគេសន្សំមកឬទេ ដែលនឹងឃើញប្រយោជន៍របស់ព្រះធម៌ សូម្បីតែ មួយពាក្យ។ អ្នកខ្លះ ពាក្យមួយម៉ាត់ក៏មិនស្ដាប់ មិនស្ដាប់ឡើយ ដូចជាខាតពេល ដូចជា អត់មានតម្លៃ ប៉ុន្តែដឹងអត់ថា ទំរាំនឹងបានឮពាក្យនេះ ត្រូវតែជាអ្នកដឹងថាអ្វីអាក្រក់ អ្វីល្អ និងមានការរឹងមាំគង់វង្ស ដែលនឹងរកផ្លូវឲ្យសេចក្ដីមិនល្អដែលនៅមាន មិនឲ្យកម្រើក មិនអាចធ្វើអន្តរាយដល់ខ្លួននិងអ្នកដទៃបាន ត្រូវស្ដាប់ក្នុងហេតុផល ព្រោះដូច្នោះ តាមពិតរបស់ផ្សេងៗទាំងនេះ ប្រសិនបើយើងចាប់ផ្ដើមបង្រៀនគ្នាតាំងតែពីក្មេង គេអាចចាប់ផ្ដើមយល់បានម្ដងបន្តិចៗ មិនច្រើនពេកទេ។ សៀវភៅរៀនមានអរិយសច្ចធម៌ ប៉ុន្តែមិនដឹងអ្វីឡើយ បានតែឈ្មោះ។

**ឌីជេ** ៖ អ្នកដែលបង្រៀនអាចនឹងមិនយល់ដែរឬទេ បាទ?

**សុចិន្ត** ៖ ប្រាកដហើយ ចាស ព្រោះហេតុថាបើយល់គ្រប់ពាក្យ ត្រឹមត្រូវតាមដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្ដែងទុកល្អហើយ ផ្ទៀងផ្ទាត់បានជាមួយនឹងពាក្យដែលចារឹកទុកជាព្រះត្រៃបិដក និងអ្វីដែលកំពុងប្រាកដថាត្រូវគ្នា។

**ឌីជេ** ៖ ភ័យដែលយើងនឹងត្រូវខ្លាចពិតៗ ឬយើងនឹងឆ្លងផុតការភ័យខ្លាចត្រង់នេះបាន ក៏គឺការមិនដឹងមែនទេ បាទ?

**សុចិន្ត** ៖ ប្រាកដហើយចាស ព្រោះហេតុថា បើមិនមានការចេះដឹង ឬដឹងខុស យល់ខុស បំផ្លាញការពិត ត្រូវសូមទោសផង ដែលនឹងសូមនិយាយដល់សំណាក់បដិបត្តិ មិនដឹងថាលោកឪជេនឹងទទួលស្តាប់ឬទេ ចាស?

**ឪជេ** ៖ បានបាទ អញ្ជើញ បាទ។

**សុចិន្ត** ៖ ព្រោះហេតុថានៅក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធជាម្ចាស់មិនបានឲ្យនរណាទៅទីណាឡើយ ដើម្បីទៅអង្គុយច្រើនម៉ោង ឬទៅដេក ទៅឈរ ហើយដឹងអ្វី? ព្រោះថាព្រះអង្គទ្រង់បំពេញព្រះបារមីមកទំរាំតែបានត្រាស់ដឹងយូរប៉ុណ្ណា ខណៈពេលដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថាទីបង្ករព្យាករណ៍ លោកសុមេធតាបស ដែលនឹងអាចជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គនេះថា នៅ៤អសង្ខេយ្យកប្បទៀត លោកនេះនឹងបានដឹងអរិយសច្ចធម៌ ជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះនាមថា ព្រះសមណៈគោតម។ ប្រជា-ជននៅសម័យនោះពេលដែលបានឮ រីករាយសប្បាយចិត្តថា បើមិនអាចដឹងអរិយសច្ចធម៌នៅសម័យព្រះសម្មាសម្ពុទ្ធជាម្ចាស់ទីបង្ករ ក៏នៅមានសម័យ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គនេះ ដែលគេអាចយល់បាន។ ទំរាំសុមេធតាបសក្នុងមួយ ជាតិៗ ដែលបានឆ្លងកាត់មក ៤អសង្ខេយ្យ១សែនកប្ប បានជួបព្រះសម្មាសម្ពុទ្ធជាម្ចាស់២៤ព្រះអង្គ តែគេនៅរង់ចាំបាន។ ប៉ុន្តែអ្នកនៅសម័យនេះមិនដឹងអ្វីសោះឡើយ ហើយក៏ទៅ ហើយក៏ធ្វើ អ្វីដែលត្រឹមត្រូវទៅ? ប្រាប់ឲ្យធ្វើ តើយល់ឬទេ? មិនបាន យល់អ្វីឡើយ ហើយធ្វើបានទាំងដែលមិនយល់ ហើយក៏សង្ឃឹម។ ប៉ុន្តែបើសួរអ្នកដែល ធ្វើហើយថា ធ្វើហើយបានអ្វី? ចម្លើយគឺថាសប្បាយចិត្ត សម្រាប់អ្នកដែលមិនដឹងអ្វីឡើយ ឯសម្រាប់អ្នកដែលស្តាប់ព្រះធម៌ ក៏ទៅសង្ឃឹមថា នឹងប្រច័ក្សការកើតរលត់ នឹងអស់កិលេស នឹងបានត្រាស់ដឹងសភាវធម៌។ ទៅយកពីណាមក ស្តាប់នៅមិនទាន់យល់អ្វីឡើយ ហើយនឹងទៅយកបញ្ញាឯណាមកដឹងនូវសភាវធម៌ពេលនេះ ដែលកំពុងតែកើតរលត់ ដោយមិនចាំបាច់ទៅណាឡើយ ព្រោះជាបញ្ញា។ នេះក៏ផ្សេងពីគ្នាហើយ មែនទេ ចាស? ព្រោះដូច្នោះ ពេលនេះក៏ចាប់ផ្តើមស្គាល់គ្នាហើយថា ពុទ្ធសាសនិកជនជានរណា? មានន័យថាដូចម្តេច? ពុទ្ធៈគឺបញ្ញា បើមិនមានបញ្ញាដឹងថាការពិតគឺជាអ្វី ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងទុកថា ដូចម្តេច? គេជាពុទ្ធសាសនិកជនឬទេ? ព្រោះពុទ្ធៈ គឺអ្នកចេះដឹង។

នេះឯង ចាស ដែលយើងត្រូវតែជាបុគ្គលត្រង់ នឹងព្រមទទួលការពិតដែលនឹងដោះស្រាយ ព្រោះហេតុថាបើធ្វើទៅដោយការមិនដឹង ផលគឺមិនដឹង ហើយការមិនដឹងនោះក៏នាំមកនូវទោសជាច្រើនប្រការ។

**ឌីជេ** ៖ បើអញ្ចឹងការដែលបបួលគ្នាទៅបដិបត្តិ ទៅអង្គុយសមាធិ ទៅស្តាប់ធម៌ យើងមិនអាចកាន់យកបានថា ជាការដែលចាប់ផ្តើម ដែលនឹងផ្តើមដឹងព្រះពុទ្ធសាសនាឬទេ បាទ?

**សុចិន្ត** ៖ សំណាក់បដិបត្តិធ្វើអ្វី ចាស? ទៅហើយធ្វើអ្វី?

**ឌីជេ** ៖ ទៅអង្គុយ។

**សុចិន្ត** ៖ ហេតុអ្វីអង្គុយ ចាស? ពេលនេះក៏អង្គុយ។

**ឌីជេ** ៖ ធ្វើតាមវិធីសាស្រ្តដែលគេបង្រៀន។

**សុចិន្ត** ៖ នរណាគឺជាអ្នកបង្រៀន?

**ឌីជេ** ៖ គឺជាគ្រូសមាធិជាអ្នកបង្រៀន បាទ។

**សុចិន្ត** ៖ គ្រូសមាធិជានរណា?

**ឌីជេ** ៖ ពិបាកឆ្លើយណាស់ បាទ។

**សុចិន្ត** ៖ ឃើញអត់ ចាស ព្រោះដូច្នោះ ទៅដោយការមិនដឹង ផលគឺការមិនដឹង។

**ឌីជេ** ៖ ព្រោះយើងមិនដឹង ទើបយើងចាត់ទុកថាគេជាគ្រូជាអ្នកចេះដឹង។

**សុចិន្ត** ៖ ហើយចុះព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកយ៉ាងដូចម្តេច?

**ឌីជេ** ៖ យើងមិនបានសិក្សាព្រះធម៌ យល់តែតាមខ្លួនឯង។

**សុចិន្ត** ៖ ព្រោះដូច្នោះ ខុសទេបើសិនជាយល់ដោយខ្លួនឯង មិនចាំបាច់សិក្សាពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែលមានជម្រៅជ្រៅណាស់។

**ឌីជេ** ៖ បើមិនសិក្សាពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏មិនរាប់ថាជាព្រះពុទ្ធសាសនា។

**សុចិន្ត** ៖ ពិតហើយ ចាស ហើយអ្នកដែលទៅសំណាក់បដិបត្តិ ស្តាប់ពាក្យអ្វី? របស់នរណា? ព្រះសម្មាសម្ពុទ្ធជាម្ចាស់មិនបានឲ្យនរណាទៅអង្គុយ មិនបានឲ្យនរណាទៅឈរ មិនបាន

ឲ្យទៅអត់ដេកអត់ពួន ឬអ្វីបែបនោះឡើយ។ មានវិបស្សនាចារ្យម្នាក់ ឈ្មោះថាវត្ត ពេលនេះក៏មិនមែនជាវិបស្សនាចារ្យ (គ្រូបង្រៀនវិបស្សនា) ទៀតឡើយ ព្រោះហេតុដែលបានយល់ការពិតសន្សឹមៗ ដឹងហើយថាខុសទាំងអស់ ព្រោះពេលដែលមិនដឹង នឹងបង្រៀនអ្វី ក៏បង្រៀនអ្នកដែលទៅបដិបត្តិដកស្មៅ ហើយចេះដឹងអ្វីទេ?

**ឌីជេ** ៖ ដកស្មៅនឹងអាចដឹងអ្វី បាទ?

**សុចិន្ត** ៖ ក៏ហ្នឹងហើយ ចាស ក៏ព្រោះគេមិនដឹង ប៉ុន្តែគាត់ជាវិបស្សនាចារ្យមានលិខិតបញ្ជាក់ទុកជាច្រើនសន្លឹក។

**ឌីជេ** ៖ បើអញ្ចឹង ទីណាទៅដែលនឹងអាចធ្វើឲ្យដឹងពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់បាន មែនទេ?

**សុចិន្ត** ៖ ព្រះធម៌បានសម្តែងហើយគ្រប់គ្រាន់ ទាំងព្រះវិន័យ ព្រះសុត្ត និងព្រះអភិធម្ម ទាក់ទងគ្នាទាំងអស់ និយាយដល់រឿងដែលមានពិតគ្រប់កាលសម័យ ពេលនេះក៏ពិត។

**ឌីជេ** ៖ គឺរៀនព្រះត្រៃបិដក។

**សុចិន្ត** ៖ ពិតប្រាកដ ចាស ព្រោះថានៅពេលដែលទ្រង់ត្រាស់ដឹង ត្រាស់ថាធម្មៈជ្រាលជ្រៅលំបាកដែលនឹងដឹងបាន នេះគឺជាពាក្យរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ពេលដែលត្រាស់ដឹងហើយ ហើយយើងមិនគិតដល់ពាក្យនេះសោះឬទេ ចាស? ទំរាំតែបំពេញ ព្រះបារមី ទំរាំតែដឹងការពិត ដឹងការពិតហើយត្រាស់ពាក្យនេះ ខណៈពេលដែល ត្រាស់សម្តែង ទ្រង់ឃើញភាពជ្រាលជ្រៅដ៏យ៉ាងក្រៃលែង។ ដែលពោលថា មិនបង្អោនព្រះទ័យ នឹងសម្តែង មិនមែនព្រះអង្គមិនទ្រង់សម្តែងទេ ប៉ុន្តែខណៈដែលភាពជ្រាលជ្រៅ យ៉ាងនោះ ដែលព្រះអង្គបានត្រាស់ដឹងហើយធ្វើឲ្យដឹងដល់ភាពជ្រាលជ្រៅថា លំបាក ដែលនឹងដឹងបាន។ ប៉ុន្តែអ្នកដែលដឹងបានមាន ទើបទ្រង់សម្តែងធម៌ ហើយព្រះព្រហ្មក៏ទ្រង់អារាធនា ឲ្យសម្តែងផង។

**ឌីជេ** ៖ នោះគឺជារឿងដែលល្អិតល្អន់ណាស់ និងយល់បានដោយលំបាក យើងនឹងធ្វើការយល់បានយ៉ាងដូចម្តេច? ចេញពីទីណា បាទ?

**សុចិន្ត** ៖ លោកឌីជេបានឮពាក្យថា "បារមី" មែនទេចាស?

**ឌីជេ** ៖ បានឮ បាទ។

**សុចិន្ត** ៖ ហើយមានន័យថាអ្វី? ឃើញទេ ចាស មួយពាក្យយើងមិនបានគិតដល់ភាពជ្រាលជ្រៅរបស់ពាក្យនោះឡើយ។ បារៈ គឺច្រាំង បារមីគឺដល់ច្រាំង ។ ច្រាំងណាទៅ ចាស? ច្រាំងនេះពេញដោយកិលេស កិលេសនៅឯណា? នៅក្នុងចិត្ត ចាសហើយទំរាំតែចិត្តលះកិលេសដល់ច្រាំងម្ខាងទៀត មិនមានកិលេសឡើយ យូរប៉ុណ្ណា? បារមីទាំងអស់។ បារមីក៏មិនមាន មិនស្តាប់ព្រះធម៌ មិនយល់អ្វីឡើយទាំងអស់ មិនមានវិរិយៈ មិនមានសេចក្តីព្យាយាម មិនមានសច្ចភាពពិតប្រាកដ មិនមានអធិដ្ឋានភាពមាំមួនពិតប្រាកដ ដែលនឹងដឹងការពិត ទាំងអស់នេះមិនមានឡើយ ហើយក៏នឹងលះសេចក្តីទុក្ខ នឹងទៅសំណាក់បតិបត្តិទៅធ្វើអ្វី? ពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ នៅឯណា? ព្រះអង្គសម្តែងរឿងបារមីឬទេ? ព្រះអង្គទ្រង់បំពេញព្រះបារមីប៉ុន្មាន ទើបអាចដឹងការពិតបាន? សូម្បីតែព្រះអគ្គសាវ័កទាំងឡាយ ព្រះមហាសាវ័កទាំងឡាយ ក៏បំពេញបារមីមក ផ្សេងគ្នាទាំងអស់ ហើយមនុស្សសម័យនេះយល់អ្វី សូម្បីត្រឹមមួយពាក្យ ឬទេ? ប៉ុន្តែក៏បបួល គ្នាទៅសំណាក់បដិបត្តិ។

ព្រោះដូច្នោះ នេះជាភ័យឬទេ ចាស? ភ័យនោះមិនមែនត្រឹមតែជំងឺនេះឡើយ ដែលអាចនឹងមិនប៉ុន្មានថ្ងៃក៏អាចបាត់ទៅវិញបាន ឬអាចនឹងយ៉ាងម៉េចក៏តាមហេតុបច្ច័យ តែអាចបាត់វិញបាន ប៉ុន្តែភ័យគឺ ការមិនដឹង នឹងបាត់ទៅដោយយ៉ាងណា សន្សំច្រើនឡើងៗ បន្ថែមឡើង បើមិនស្គាល់ពីព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បំពេញបារមីមកដើម្បី នរណា ដើម្បីសម្តែងធម៌ដែលព្រះអង្គត្រាស់ដឹង ជាមួយនឹងអ្នកដែលអាចយល់បាន ព្រោះគេគិតខ្លួនឯងមិនបានជាប្រាកដ។ ធម្មៈជ្រាលជ្រៅដ៏យ៉ាងក្រៃលែង។

**ឌីជេ** ៖ តើព្រះពុទ្ធសាសនាមានភ័យឬទេ បាទ?

**សុចិន្ត** ៖ មាន ចាស។

**ឌីជេ** ៖ គឺអ្វី បាទ?

**សុចិន្ត** ៖ ការយល់ឃើញខុស។

**ឌីជេ** ៖ យ៉ាងដូចម្តេច បាទ?

**សុចិន្ត** ៖ ឃើញថាព្រះពុទ្ធសាសនាងាយស្រួល ឃើញថាមិនចាំបាច់សិក្សា ធ្លាប់បានឮមកទេ ចាស?

**ឌីជេ** ៖ មិនបាច់សិក្សា?

**សុចិន្ត** ៖ ជ្រាលជ្រៅដ៏យ៉ាងក្រៃលែង ត្រូវសិក្សា។ ឃើញទេ ចាស ផ្សេងគ្នាហើយ អ្នកដែលមិនសិក្សា ហេតុអ្វីមិនសិក្សា? គិតខ្លួនឯង នឹងមានបញ្ញាស្មើនឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ឬ? សូម្បីតែមួយពាក្យឆ្លើយមិនបានឡើយ ធម្មៈគឺអ្វី? ក៏ឆ្លើយមិនបាន។ អរិយៈសច្ចគឺអ្វី? ក៏អរិយសច្ច និងធម្មៈផងដែរ គ្រប់យ៉ាងជាធម្មៈទាំងអស់។ ធម្មៈមានទាំងកុសលធម៌ អកុសលធម៌ អព្យាកតធម៌។ បុណ្យសពក៏បានឮតែរហូតមកមែនទេ ចាស? កុសលធម្មា អកុសលធម្មា អព្យាកតាធម្មា ហើយម៉េចទៅ? នរណាស្តាប់ នរណាយល់ នរណាដឹង ហើយក៏ទៅសំណាក់បដិបត្តិ គេគិតថាអាចធ្វើឲ្យអ្នកដទៃអស់កិលេសបានឬ? នៅពេលដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងព្រះធម៌ ៤៥វស្សា ច្រើនជាងគេ អាចនិយាយបានថាស្ទើរតែរាល់ថ្ងៃ ព្រឹកព្រលឹម ថ្ងៃ ល្ងាច យប់ទេវតាមកទូលសួរបញ្ហា បើមិនដូច្នោះយើងក៏គ្មានឱកាសបានឮសូម្បីមួយពាក្យ បើទ្រង់មិនត្រាស់ដឹង មិនទ្រង់ត្រាស់សម្តែងទុក។ ព្រោះដូច្នោះ មិនថាអ្នកណានឹងនិយាយថាអ្វីក៏ដោយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទុកថាដូចម្តេច? ធម៌ទាំងឡាយជាអនត្តា។ សង្ខារទាំងមិនទៀង សង្ខារទាំងឡាយជាទុក្ខ ធម៌ទាំងឡាយជាអនត្តា តែមួយពាក្យៗផ្សេងគ្នាមែនទេ? សង្ខារធម៌ សង្ខារធម៌ តែពាក្យចុងក្រោយមិនរៀរឡើយ គឺធម្មៈទាំងឡាយ មិនថានឹងជាសង្ខារធម៌ ឬវិសង្ខារធម៌ ឬអសង្ខតធម៌។ ទាំងអស់ជាព្រះមហាករុណាយ៉ាងក្រៃលែង ដែលទ្រង់សម្តែងយ៉ាង ល្អិតល្អន់ ព្រោះដឹងថាការមិនដឹងរបស់មនុស្សសន្សំមកយូរណាស់ នេះគឺភ័យមែនទេ? ដែលមិនដឹងសោះឡើយថា អ្វីជាអ្វី ទើបបានទៅធ្វើរឿងដែលមិនល្អ ទុច្ចរិតគ្រប់កន្លែង ព្រោះអ្វី ហើយនឹងដោះស្រាយគ្នាយ៉ាងដូចម្តេច ចាស? បើសិនជាមិនយល់ការពិត ក៏ដោះស្រាយ មិនបាន ព្រោះដូច្នោះ បើមិនដឹងការពិត តើនឹងអាចជាមនុស្សល្អបានឬទេ? នឹងរៀរអំពើអាក្រក់បានឬទេ?

**ឌីជេ** ៖ ទីបំផុតនោះភ័យដែលកើតឡើងដល់ព្រះពុទ្ធសាសនាបើដល់ទីបំផុត ហើយនឹងកើតអ្វីឡើងបាទ?

**សុចិន្ត** ៖ ប្រើពាក្យថា "ព្រះពុទ្ធសាសនា" មានន័យថាជាពាក្យបង្រៀនប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់។ ព្រោះដូច្នោះ ភ័យដែលនឹងកើតដល់ព្រះពុទ្ធសាសនា គឺបំផ្លាញពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដោយការមិនសិក្សាព្រះធម៌ ដោយសេចក្តីគោរពត្រូវតែជាអ្នកល្អិតល្អន់ និងគោរពដ៏យ៉ាងក្រៃលែង ដែលនឹងត្រូវពិចារណាព្រះធម៌ទាំងអស់តែមួយពាក្យ តែមួយយ៉ាង ឲ្យទាក់ទងគ្នាទាំងបិដកទាំង៣ ដូចដែលពោលថា គ្រប់យ៉ាងដែលមានពិតជាធម្មៈ ក៏មានអ្នកទៅប្រាប់ថា ខ្លះជាអត្តា និយាយបានដូចម្តេច ទៅ? នៅ

ពេលដែលព្រះអង្គត្រាស់ថា ធម្មទាំងឡាយ មិនរៀរឡើយ ជាអនត្តា។ ហើយក៏មានអ្នកប្រាប់ថាខ្លះជាអត្តា គេជានរណា? ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជានរណា? ហើយសាកល្បងពិចារណាការពិតមើលថា អ្វីដែលត្រឹមត្រូវ នរណាទៅបង្គាប់បញ្ជាអ្វីបាន មិនឲ្យខឹងបានអត់? មិនឲ្យជាប់ជំពាក់បានអត់? មិនឲ្យទុក្ខបានអត់? មិនឲ្យឃើញបានអត់? កំពុងបានឮយ៉ាងនេះ មិនឲ្យបានឮបានអត់? ឃើញទេ ចាស? មិនយល់នៅក្នុងសភាពជា អនត្តានៃគ្រប់យ៉ាងដែលកើតបាននៅពេលមានហេតុបច្ច័យដែលសមគួរប៉ុណ្ណោះ បើសិនជាមិនមានបច្ច័យដែលសមគួរ ក៏កើតមិនបាន។ មិនមានភ្នែកនឹងទៅធ្វើដូចម្ដេចឲ្យឃើញ មិនមានផ្លូវទៅរូច ឬមាន ចាស?

**ឌីជេ** ៖ មិនមានទេ បាទ។

**សុចិន្ត** ៖ ទៅរកពេទ្យពូកែវិសេសដែលនឹងអាចធ្វើបាន ប្រសិនបើមិនមានកម្មដែលនឹងធ្វើឲ្យ ចក្ខុបសាទកើតឡើង នរណាក៏ធ្វើមិនបានដែរ ព្រោះសូម្បីតែរូប របស់ដែលមិនអាចដឹងនូវអ្វីបានឡើយ ជារូបធម៌ រូបខ្លះកើតពីកម្ម រូបខ្លះកើតពី ចិត្ត រូបខ្លះកើតពីឧតុ ភាពត្រជាក់ភាពក្ដៅ រូបខ្លះកើតពីអាហារ នេះហើយដែលឲ្យសត្វលោករស់នៅបានដោយអាហារ ដែលទំពារហូបចូលទៅ ដែលជាអាហារមួយប្រភេទ ប៉ុន្តែនៅមានអាហារដទៃទៀត។

**ឌីជេ** ៖ មើលទៅពាក្យឆ្លើយរបស់លោកអាចារ្យសុចិន្ត ក៏មាននៅក្នុងខ្លួនហើយថា នរណាដែលធ្វើឲ្យយើងមិនដឹង មិនដឹងសូម្បីតែព្រះពុទ្ធសាសនា ប្រសិនបើរកផ្លូវចេញ ប្រសិនបើនឹងការពារភ័យដែលនឹងកើតឡើង យើងត្រូវតែសិក្សាព្រះធម៌ឲ្យគ្រប់ ជ្រុងជ្រោយ។

**សុចិន្ត** ៖ ដោយក្ដីគោរពដែលយើងត្រូវយល់ឲ្យបានត្រឹមត្រូវ ហើយជួយគ្នា បំនុកបម្រុងពាក្យទូន្មាន ដែលប្រសិនបើអន្តរធានទៅហើយ ក៏យូរសែនយូរ ពិបាកនឹងបានឮ បានស្គាល់ទៀតនៅក្នុងសង្សារវដ្ត។ ព្រោះដូច្នោះ ជារបស់ដែលមានតម្លៃបំផុត ប៉ុន្តែប្រសិនជាយើងមានសំណាក់បដិបត្តិ ឬដោយមានការសិក្សា ដែលអ្នកនោះជាអ្នកប្រាប់ យ៉ាងនេះយ៉ាងនោះ ប៉ុន្តែមិនមែនជាអ្វីដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែង ទុកល្អហើយនោះជាការបំផ្លាញពាក្យទូន្មានរបស់ព្រះអង្គ ជាភ័យទេ?

**ឌីជេ** ៖ ជាភ័យ បាទ។

**សុចិន្ត** ៖ ហើយគ្រប់យ៉ាងមិនមានភ័យអ្វីខ្លាំងជាងការដែលមិនដឹង ព្រោះគ្រប់គ្នា ចង់មានចង់សុខ ចង់សប្បាយ ប៉ុន្តែមិនដឹង ក៏ធ្វើហេតុដែលមិនល្អ។ មានរោគភ័យផ្សេងៗ

កើតមានឡើងពេញពិភពលោក នឹងការពារយ៉ាងដូចម្ដេច នឹងដោះស្រាយដូចម្ដេច បើសិនជារបស់ កើតពីឧតុ កែបានអត់? មែនទេ ចាស? ក៏មានការសិក្សាមុខវិជ្ជាផ្សេងៗ ប៉ុន្តែអ្វីដែលមិនមាន នរណាព្យាបាលបានគឺកម្ម បើសិនជាកម្មអាក្រក់ធ្វើយ៉ាងណានឹងឲ្យផលដ៏ល្អមិនបាននោះ។

**ឌីជេ** ៖ បើសិនជាកម្មល្អ ក៏នឹងល្អ។

**សុចិន្ត** ៖ នរណាក៏មិនអាចហាមផលល្អកើតក៏មិនបាន យើងក៏ឃើញស្រាប់ហើយ កើតមកច្រើនបែបខុសគ្នាគ្រប់យ៉ាង រូបរាង មុខមាត់ ពណ៌សម្បុរ ឋានៈ យស បណ្ដាស័ក្ដ កិត្តិយស ការចេះដឹងគ្រប់ប្រការទាំងអស់ ចាស មិនដូចគ្នាឡើយ សូម្បីតែមួយ សូម្បីតែមនុស្សម្នាក់ៗ នេះគឺជាភាពល្អិតល្អន់ដ៏ក្រៃលែងរបស់ព្រះធម៌។ ចិត្តមួយខណៈកើតហើយរលត់វិញ មិនបានស្ទួនជាមួយចិត្តខណៈតទៀតដែលនឹងកើត បច្ច័យដែលនឹងតាក់តែងពីការដែលចិត្តនោះកើតហើយ ឃើញអ្វី ដឹងអ្វី គិតអ្វី បន្តទៅចិត្តខណៈតទៅទៀត។ ព្រោះដូច្នោះក៏ទើបមានមុខវិជ្ជាផ្លូវលោកជាច្រើនមហាសាល មិនចេះចប់ ប៉ុន្តែចំណែកឯផ្លូវព្រះធម៌វិញ ជ្រាលជ្រៅដ៏ក្រៃលែងជាងនោះឆ្ងាយណាស់ ហើយមិនសិក្សាឡើយ ព្រោះដូច្នោះ រាល់ថ្ងៃក៏នឹងអស់ទៅ បើសិនជាមិនមានការរក្សាទុកដោយសេចក្ដីគោរព។ គឺត្រូវតែជា បុគ្គលត្រង់ជាមួយការពិត និងជាមួយពាក្យដែលព្រះអង្គទ្រង់ត្រាស់ទុក ព្រោះបានត្រាស់ដឹងដល់ថ្នាក់ជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ មិនមាននរណាដឹងជាងព្រះអង្គឡើយនៅក្នុងសកលចក្រវាលមានព្រះសម្មាសម្ពុទ្ធជាម្ចាស់បានតែម្ដង មួយព្រះអង្គប៉ុណ្ណោះ។

**ឌីជេ** ៖ សាធុ បាទ ជាឱកាសក្រោយម្ដងទៀត នឹងបាននិយាយសន្ទនាជាមួយអាចារ្យ និងបានទទួលការចេះដឹងគំនិតបន្ថែម ដែលនៅមានរឿងជាច្រើនយ៉ាងដែលនឹងត្រូវទៅពិចារណាតទៅទៀត ទៅសិក្សាទៅរៀនដឹងតទៀត បាទ ដូចដែលលោកអាចារ្យបានប្រាប់រឿងរបស់ការសិក្សាព្រះធម៌យ៉ាងគោរពនិងសិក្សាឲ្យគ្រប់ជ្រុងជ្រោយ ក្នុងបិដកទាំង ៣។

**សុចិន្ត** ៖ ចាស ព្រោះថារាល់គ្នាក៏ត្រូវលាលោកនេះទៅ នឹងដោយរោគដែលកំពុងរាលត្បាតនៅពេលនេះ ឬអត់ ឬអ្វីក៏តាមហ្នឹងចុះ ប៉ុន្តែក៏ត្រូវស្លាប់ដូចគ្នា ហើយពេលដែលស្លាប់យើងនឹងមិនមានអ្វីទៅដល់ជាតិតទៅទៀត ដែលជាគុណនៃសេចក្ដីល្អ និងការយល់ត្រឹមត្រូវ ឬនៅពេលដែលមានឱកាស រវល់តែខ្លាចអ្វី មែនទេ ចាស? ប៉ុន្តែមិនខ្លាចភាពមិនដឹងសាកប្រៀបធៀបគ្នាមើល ភាពមានដឹងគួរឲ្យខ្លាចជាងប៉ុណ្ណា។

**ឌីជេ** ៖ ពិត បាទ។ ការមិនដឹង ខ្ញុំមិនធ្លាប់បានឮនរណានិយាយដល់រឿងភ័យខ្លាច ភាពមិនដឹងដូចជាអាចារ្យឡើយ។

**សុចិន្ត** ៖ ព្រោះមិនដឹង ក៏មិនខ្លាច។

**ឌីជេ** ៖ នៅខណៈដែលខ្លាចរឿងគ្រប់យ៉ាង គ្រប់ពេលវេលា ខ្លាចភាពងងឹត ខ្លាចខ្មោច ខ្លាចក្រ ខ្លាចឈឺ ខ្លាចស្លាប់ ប៉ុន្តែមិនធ្លាប់បានឮនរណានិយាយថា ខ្លាចការមិនដឹង។

**សុចិន្ត** ៖ ចាស ព្រោះដូច្នោះនឹងរួចផុតពីទោសភ័យផ្សេងៗបានអត់នៅពេលមិនដឹង?

**ឌីជេ** ៖ មិនបានទេ បាទ។

**សុចិន្ត** ៖ ព្រោះដូច្នោះពិភពលោកក៏ជាយ៉ាងនេះ ចាស តាមដែលយើងឃើញ ព្រោះដូច្នោះព្រះធម៌គឺការយល់ការចេះដឹង ជាប្រយោជន៍ទាំងដល់ខ្លួនឯង និងអ្នកដទៃផងដែរ។ ប្រយោជន៍ប៉ុណ្ណាទៅ ចាស ?

**ឌីជេ** ៖ ប្រយោជន៍ទាំងអស់ ។

**សុចិន្ត** ៖ ប្រយោជន៍ទាំងខ្លួនឯង និងទាំងអ្នកដទៃផងដែរ ។

**ឌីជេ** ៖ ក៏គឺគ្រប់គ្នា ។

**សុចិន្ត** ៖ បើសិនគ្រប់គ្នាដឹងយ៉ាងនេះ ប្រយោជន៍ក៏មហាសាល ។

**ឌីជេ** ៖ ជាចុងក្រោយបំផុតនេះ លោកអាចារ្យសុចិន្ត នឹងមានមតិដល់ពុទ្ធសាសនិកជនយ៉ាងណាខ្លះ បាទ?

**សុចិន្ត** ៖ ចាស ជាបុគ្គលត្រង់។ ពុទ្ធៈគឺអ្នកដឹង ដឹងនូវអ្វីដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់បានទ្រង់ត្រាស់សម្ដែង ដើម្បីឲ្យយើងយល់នូវអ្វីដែលយើងមិនអាចគិតដោយខ្លួនឯងបានឡើយ ។ ព្រោះដូច្នោះ ការសិក្សានូវរាល់ពាក្យត្រូវ តែល្អិតល្អន់ជ្រាលជ្រៅ និងត្រូវយល់ដោយរហូតដល់ពិតប្រាកដទាំងបិដកទាំង៣ ដែលទាក់ទងគ្នា មិនមែនយុគសម័យនេះភិក្ខុកាន់លុយបាន បានយ៉ាងដូចម្ដេចទៅ? ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ បញ្ញត្តិទុកហើយគ្រប់ប្រការថា ជីវិតដែលលះបង់ភេទជាគ្រហស្ថ លះបង់ហើយនូវភាពសប្បាយរីករាយដូចជាភេទគ្រហស្ថ ហើយបែរទៅកាន់មាសប្រាក់បានទៀតឬ? ព្រោះហេតុថាការបួសជាព្រះភិក្ខុ បព្វជាមានន័យថា លះគ្រប់យ៉ាង។ ព្រោះដូច្នោះ បើបានសិក្សាព្រះវិន័យពិតៗ នឹងដឹងថាប្រព្រឹត្តទៅដើម្បី ការលះបង់ ព្រោះឃើញទោសនៃភាពមិនដឹង

និងកិលេសនោះ គឺសាវ័កលោកប្រើពាក្យថា ជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលកើតចេញពីព្រះឱស្ឋ ចេញពីបញ្ញា ការដឹងរបស់ព្រះអង្គ ដែលអាចឲ្យអ្នកដទៃឃើញគុណប្រយោជន៍នៃការលះបង់នូវភេទជាគ្រហស្ថ ឆ្ពោះទៅភេទដែលតម្រង់ទៅរកការ សិក្សាព្រះធម៌ និងអប់រំចម្រើនបញ្ញា ដើម្បីកម្ចាត់បង់កិលេស ដើម្បីប្រយោជន៍ខ្លួនឯង និងពិភពលោកផងដែរ។ ប៉ុន្តែនេះក៏មិនមែន ជារឿងសម្រាប់មនុស្សគ្រប់គ្នា ព្រោះគ្រហស្ថ ក៏មិនមានអធ្យាស្រ័យ ដែលនឹងមានជីវិតដូចជាបព្វជិត អាចយល់ធម៌ជាព្រះសោតាបន្ន ដូចជាពេទ្យជីវកោមារភត្ត។ គ្រហស្ថក្នុងសម័យនោះ ក៏ជាព្រះអរិយបុគ្គលច្រើនរូបណាស់ នឹងអាចដឹងការពិតដល់ថ្នាក់ព្រះអានាគាមី អាចនៅជាភេទគ្រហស្ថបាន តែនៅពេលណា ដែលបន្លុះគុណធម៌ជាព្រះអរហន្តហើយនោះ នឹងមិនគ្រប់គ្រងផ្ទះទៀតឡើយ នឹងលះបង់ភេទជាគ្រហស្ថ ឆ្ពោះទៅរកភេទបព្វជិត។ ព្រោះដូច្នោះ សំពត់កាសាវពស្ត្រ គឺភេទបព្វជិត គឺគ្រឿងសម្គាល់របស់ព្រះភិក្ខុដែលជាព្រះអរហន្ត ប៉ុន្តែបើនៅមិនទាន់ជាព្រះអរហន្ត ក៏ សិក្សាដើម្បីកម្ចាត់បង់កិលេស ទាំងដែលជាឃរាវាស គ្រហស្ថក៏សិក្សាបានដែរ ប៉ុន្តែត្រូវ ប្រព្រឹត្តទៅតាមអធ្យាស្រ័យ តាមហេតុបច្ច័យដែលបានសន្សំមក។ ព្រោះដូច្នោះ ពុទ្ធបរិស័ទនៅសម័យនោះទើបមាន ៤ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា។ ដោយនៅ សម័យនេះព្រះអង្គទ្រង់ឃើញថាស្ត្រីមិនសមនឹងជាភេទបព្វជិត ប៉ុន្តែនៅសម័យនោះ នៅពេលព្រះអានន្ទ ទូលសូមថា ស្ត្រីអាចបន្លុះគុណធម៌ដល់ ថ្នាក់ជាព្រះអរហន្តបាន នៅកាលនោះក៏ទ្រង់អនុញ្ញាត ប៉ុន្តែតឹងរឹងខ្លាំងណាស់ក្នុងការដែលឲ្យជាភិក្ខុនី រហូតដល់ ភិក្ខុនីក៏អស់ទៅជាបណ្តើរៗ ដោយភាពលំបាកនឹងបួសជាភិក្ខុនីបាន។ យុគសម័យនេះ ពុទ្ធបរិស័ទក៏គឺ ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា។ បើសិនជាអ្នកគោរពព្រះពុទ្ធសាសនា ពុទ្ធៈគឺអ្នកដឹង ដឹងតាមដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹង ហើយទ្រង់ព្រះមហាករុណាសម្តែងធម៌ ឲ្យយើងផ្តើមយល់ភាពមានជម្រៅដ៏ក្រៃលែង ដើម្បីថែរក្សា ព្រះធម៌ទុកដើម្បីផ្សាយតៗទៅ មិនមែនតែសំរាប់យុគនេះ សម័យនេះ តែដរាបដែលព្រះពុទ្ធសាសនាស្ថិតនៅបាន ដើម្បីប្រយោជន៍ខ្លួនឯង និងអ្នកដទៃ និងគ្រប់ជាតិសាសន៍ នៅក្នុងលោក ។

គួរឲ្យសោកស្តាយ បើសិននឹងមិនមាននរណាសិក្សា ព្រះពុទ្ធសាសនាក៏នឹង អន្តរធាន។

**ឌីជេ** ៖ អរព្រះគុណលោកអាចារ្យសុចិន្តខ្លាំងណាស់បាទ។

**សុចិន្ត** ៖ ចាស អរគុណ ចាស។

**ឌីជេ** ៖ អរគុណ បាទ។